# PROPHETIC REVELATION



# វិវាហ
# មង្គល
# នៃកូនចៀម

ការសិក្សា
ពីគំរូ ដែលឆ្លុះបញ្ចាំង
ដោយទំនៀមទំលាប់ និង
ប្រពៃណី អាពាហ៍ពិពាហ៍

អ្នកណាដែលមានត្រចៀក ឱ្យអ្នកនោះស្តាប់ចុះ!




**វិវាហមង្គលនៃកូនចៀម**

***"ពីព្រោះខ្ញុំប្រចណ្ឌចំពោះអ្នករាល់គ្នា ដោយសេចក្តីប្រចណ្ឌនៃព្រះ ដ្បិតខ្ញុំបានបំរុងអ្នករាល់គ្នាទុក ឲ្យមានប្តីតែ១ ទុកដូចជាក្រមុំបរិសុទ្ធ គឺដើម្បីនឹងថ្វាយទៅព្រះគ្រីស្ទតែ១ប៉ុណ្ណោះ"*** ២ កូរិនថូស ១១:២ ។

*"នោះខ្ញុំឮសូរដូចជាសំលេងនៃមនុស្ស១ហ្វូងយ៉ាងធំ ដូចជាសូរទឹកច្រើន ហើយដូចសូរផ្គរលាន់យ៉ាងខ្លាំងថា ហាលេលូយ៉ា ដ្បិតព្រះអម្ចាស់ដ៏ជាព្រះដែលមានព្រះចេស្តាបំផុត ទ្រង់សោយរាជ្យឡើងហើយ ចូរឲ្យយើងអរសប្បាយ ហើយរីករាយឡើង ទាំងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតបានដល់ពេលរៀបវិវាហមង្គលនៃកូនចៀមហើយ ភរិយាទ្រង់បានរៀបខ្លួនជាស្រេច ទ្រង់ប្រទានឲ្យនាងបានស្លៀកពាក់ សំពត់ទេសយ៉ាងម៉ដ្ឋ ស្អាត ហើយភ្លឺ ដ្បិតសំពត់ទេសយ៉ាងម៉ដ្ឋ នោះជាសេចក្តីសុចរិតរបស់ពួកបរិសុទ្ធ"។* វិវរណៈ ១៩:៦-៨

## ការចាប់ផ្តើមនៃវិវាហមង្គល

វិវាហមង្គល គឺជាការចាប់ផ្តើមទី១ និងមានតែ១គត់ ដែលព្រះបានរៀបចំឡើងមុន ការដួលចុះក្នុងអំពើបាប។ ព្រះបន្ទូលពិសិដ្ឋបានបញ្ជាក់យ៉ាងច្បាស់ថា ព្រះចង់ឲ្យមនុស្សបង្ហាញការសំដែងជាប្រុស និងជាស្រី អាស្រ័យទៅលើការដឹងនាំនៃព្រះបន្ទូលរបស់ព្រះ។ (សូមអាន លោកុប្បត្តិ១:២៦-២៧, ២ : ២១-២៥, លេវីវិន័យ ២០:១០, ម៉ាថាយ ៥:២៧-២៨ )។ អាពាហ៍ពិពាហ៍ គឺជាការប្រកបយ៉ាងស្និទ្ធស្នាលនៃមនុស្ស២នាក់ គឺបុរស និងស្ត្រី។ វាគឺជាទំនាក់ទំនងអចិន្ត្រៃយ៍ ( ម៉ាថាយ ១៩:៦ )។

# ប្រពៃណី និងទំនៀបទំលាប់រៀបអាពាហ៍ពិពាហ៍

ប្រពៃណី និងទំនៀបទំលាប់រៀបអាពាហ៍ពិពាហ៍នៃគ្រប់ជនជាតិ និងសញ្ជាតិ ខុសគ្នាពី១ទៅ១។ ដូច្នេះ ដើម្បីឲ្យយើងមានការ យល់ដឹងត្រឹមត្រូវនៃអាថ៌កំបាំង នេះ ដែលទាក់ទងនឹងវិវាហមង្គលនៃកូនចៀមនៃព្រះ យើងត្រូវតែចូលមកប្រធាន បទនេះជាមួយនឹងរូបភាព នៃការរៀបចំ *អាពាហ៍ពិពាហ៍ ផ្នែកខាងអាស៊ី* ពីព្រោះ គម្ពីរជាសៀវភៅ ផ្នែកខាងអាស៊ី។ ខ្ញុំរំពឹងទុកថា មានគ្រីស្ទានខ្លះ នឹងមិនយល់ព្រម តាមខ្ញុំ ពីចំនុចល្អជាងនេះ ជាច្រើន ដែលបានបង្ហាញនៅ ក្នុងព្រះរាជសារនេះ

ប៉ុន្តែបទគម្ពីរបរិសុទ្ធ គឺជាអាជ្ញាធរ ។ អាពាហ៍ពិពាហ៍នៅ សម័យគម្ពីរ ចែកចេញជាពិធីពីរ-ពិធីភ្ជាប់ពាក្យ (ឬ ស្ដី ដណ្ដឹង) និងអាពាហ៍ពិពាហ៍។ ពាក្យយូដាសំរាប់ ព្រឹត្តិការណ៍ទាំង២នេះ គឺ ឃីឌ ឌូស៊ីន (Kiddushin)និងជុបប៉ា(Chuppah) ជាទីគោរព។ ពិធីទាំង២នេះត្រូវតែកំនត់ថ្ងៃនិងឆ្នាំឲ្យបានជាក់។ ការស្ដីដណ្ដឹង ដូច ជាការចង់ជាអាពាហ៍ពិពាហ៍ដែរ។ នៅភាគខាងកើត បន្ទាប់ ពីគ្រួសារខាង កូនក្រមុំទទួល យកការស្នើ សុំរៀបការពីកូនកំលោះហើយ នោះគេក៏ជ្រើរើស និង កំណត់ថ្ងៃភ្ជាប់ពាក្យ ត្រូវបានគេឲ្យផឹកពីពែងដូចគ្នា ដែល ការឲ្យពរពិធីស្ដីដណ្ដឹង ត្រូវប្រកាសចេញទៅ បន្ទាប់ពី ពូកគេបានទទួលពាក្យសម្បថ ដើម្បីបោះត្រា លើ ពិធីស្ដីដណ្ដឹងចំពោះគ្នាទៅវិញទៅមក។

**លោកុប្បត្តិ ជំពូក ២**

២១.នោះព្រះយេហូវ៉ា ដ៏ជាព្រះ ទ្រង់ធ្វើឲ្យអ័ដាម ដេកលក់ស៊ប់ទៅរួចទ្រង់យកឆ្អឹងជំនីរគាត់១ ហើយ ភ្ជិតសាច់ទៅវិញ។

២២.រីឯឆ្អឹង ដែលព្រះយេហូវ៉ាដ៏ ជាព្រះបានយកពី អ័ដាមមក នោះទ្រង់ជបឲ្យកើតឡើងជាមនុស្សស្រី ក៏នាំទៅឯអ័ដាម។

២៣.អ័ដាមក៏ថា នេះហើយជាឆ្អឹងពីឆ្អឹងអញ ជា សាច់ពីសាច់អញ នឹងត្រូវហៅថា "ស្ត្រី" ពីព្រោះ បានយកពីបុរសមក។

២៤.ដោយហេតុ នោះបាន ជាមនុស្សប្រុសនឹងលា ចេញពី ឪពុកម្ដាយខ្លួន ទៅនៅជាប់ នឹងប្រពន្ធវិញ ហើយ អ្នកទាំង២នោះនឹងត្រឡប់ជាសាច់តែ១សុទ្ធ ។

២៥.រីឯអ័ដាមនឹងប្រពន្ធគាត់ ក៏នៅអាក្រាតទទេ ឥតមានសេចក្ដីអៀមខ្មាសឡើយ។

ពាក្យសម្បថ នេះត្រូវថាឡើងវិញ ជាលក្ខណះពិធី នៅថ្ងៃ អាពាហ៍ពិពាហ៍ (ម៉ាថាយ ២២: ២៦-២៩) ។

ទោះជាស្ត្រីនោះ ជូនកាលហៅថា *ប្រពន្ធ* និង បុរសនោះហៅថា *ប្ដី* ក៏ដោយ ក៏ ត្រូវគេពុំទាន់រស់នៅជាមួយគ្នានៅឡើយដែរ ។ គឺ*មានតែនៅកំឡុងពេល* ការប្រារព្ធ ពិធីរៀបការប៉ុណ្ណោះ ដែលប្ដីប្រពន្ធនោះ អាចមករួមរស់ខាងផ្លូវភេទជាមួយគ្នាបាន ដើម្បីបញ្ចប់វិវាហមង្គល។ ដូច្នេះ នៅចន្លោះការស្ដីដណ្ដឹង និងពិធីរៀបការ ភាគី

វិវាហមង្គលនៃកូនចៀម

ដែលភ្ជាប់ពាក្យ ត្រូវតែស្មោះត្រង់គ្នានឹងគ្នា ។ (សូមអានលោកុប្បត្តិ ២៩:២១,ចោទិយកថា ២២:២៣-២៤,ម៉ាថាយ១:១៨-២០,ម៉ាឡាគី២:១៤,អេសេគាល១៦:៨) ។

**ការជ្រើសរើសកូនក្រមុំ**

លោកុប្បត្តិ ២៤ គឺជាជំពូក ដែលល្បីល្បាញជាងគេបំផុត នៅក្នុងបទគម្ពីរ ដែលបង្ហាញពី របៀបដែលឪពុករើសប្រពន្ធឲ្យកូនប្រុសរបស់គាត់។ ក្នុងសម័យផ្នែកខាងអាស៊ីពីបុរាណ វាជាករអនុវត្តទូទៅ ជំពោះឪពុករើសប្រពន្ធឲ្យកូនប្រុសរបស់គាត់ ជួនកាល ទោះបីជាកូនប្រុសនោះអាចបង្ហាញពីការពេញចិត្តរបស់គាត់ក៏ដោយ ។ ឪពុក ឬម្ដាយ ឬសូម្បីតែបងប្រុសច្បង ជាជម្មតា តែងតែអនុវត្តនូវការចចារ ។ ចំណងដៃ និងអំណោយអាពាហ៍ពិពាហ៍សំរាប់កូនក្រមុំ ជារបស់បេរចំបងក្នុងការចចារ។ (មើលលោកុប្បត្តិ ២៤:៥៣,៥៩,៦១, ២៩:១៨,២៤, ៣៤:១២, និក្ខមនំ ២២:១៧, ១សំយូអែល ១៨:២៥, ពួកចៅហ្វាយ១:១៥, ១ពង្សាតាក្សត្រ ៩:១៦, នាងអេសធើរ២:៩)។ មានតែក្រោយកាហះទេសះដាក់លាក់ប៉ុណ្ណោះ ដែលអ្នកកំលោះនោះធ្វើការរៀបចំដោយខ្លួនគាត់។ (មើលលោកុប្បត្តិ ២១:២១,២៤, ៣៨:៦, ៣៤:៤,៨,១១, ពួកចៅហ្វាយ ១៤:១-១០)។ នៅក្នុងករណីអ៊ីសាក ការជ្រើសរើសប្រពន្ធរបស់គាត់ត្រូវបានពន្យល់យ៉ាងច្បាស់ដោយឪពុករបស់គាត់ ដែលបានតែងតាំងអ្នកបំរើ ឈ្មោះ អេលាសើរ ដើម្បីចេញទៅរកប្រពន្ធសំរាប់សំរាប់កូនប្រុសគាត់ ហើយជាអ្នកអនុវត្តកិច្ចរចា តាងនាមឲ្យគាត់។

វាគឺជាប្រពៃណី សំរាប់កូនកំលោះ យកនរណាម្នាក់ ដើម្បីដើរតួជា អ្នកនាំពាក្យ រវាងកូនកំលោះ និងកូនក្រមុំ ។ សព្វថ្ងៃនេះ អ្នកនាំពាក្យបែបនេះ ត្រូវបានគេស្គាល់ថាជាអ្នកកំដរប្រុស។ ក្នុងសម័យគម្ពីរ គាត់ត្រូវបានគេស្គាល់ថា ជាគូកន ឬមិត្ត សម្លាញ់របស់កូនកំលោះ។ អាមមានគូកន ឫមិត្តសម្លាញ់ម្នាក់ ឬច្រើន ។ (មើល ពួកចៅហ្វាយ ១៤:១១-២០, ១៥:២ យ៉ូហាន ៣:២៩) ។ (សំគាល់: អ្នកមង្គលកា[អភិបាល នៃការទទួលអាហារ នៅក្នុងយ៉ូហាន ២:៨-៩ ក៏ជាគូកន ឬមិត្តសម្លាញ់នៃកូនកំលោះផងដែរ។]

## ព្រះយេស៊ូគ្រីស្ទ និងពួកជំនុំ

យោងទៅតាមនិម្មិតទាំងប៉ុន្មាន ដែលអ្នកបរិសុទ្ធយ៉ូហាន បានឃើញ នៅកោះប៉ាត់ម៉ុសប្រះវរបិតា ដែលគង់នៅស្ថានសួគ៌របស់យើង ជាព្រះវរបិតានៃព្រះអម្ចាស់យេស៊ូគ្រីស្ទ មានវិញ្ញាណ៧ ដែលទ្រង់ប្រទានទៅក្នុងព្រះហស្តស្តាំ នៃព្រះរាជបុត្រាដ៏មានសិរីល្អរបស់ទ្រង់(វិវរណៈ ១:៤,១៦,២០)។ វិញ្ញាណទាំង៧ (ពួកអ្នកបំរើ) គឺជាមរដកនៃព្រះរាជបុត្រា។ ពួកគេជាគំរូនៃពួកអ្នកកំដរទី១ ពួកគូកន

និងជាមិត្ត សម្លាញ់របស់ព្រះយេស៊ូគ្រីស្ទ។ ពួកគេត្រូវបានចាត់មកដោយព្រះយេស៊ូគ្រីស្ទ ដើម្បី*ទាក់ទង* ជាមួយកូនក្រមុំសាសន៍ដទៃ ចាប់តាំងពីពេលចូលស្តីដណ្តឹងរហូតដល់ពិធីរៀបការ ដើម្បីរៀបចំនាងជាស្រេច សំរាប់ការបរិភោគការដ៏ធំ ដែលនៅខាងមុខ។ មានអ្នកនាំព្រះរាជសារ៧នាក់ នៃយុគសម័យពួកចំនុំទាំង៧។ (សំគាល់ នៅពេលដែលសាសន៍យូដា បានបដិសេធដំណឹងល្អ ព្រះបានដឹងនាំអ្នកបរិសុទ្ធប៉ូល ឲ្យផ្សាយទៅពួកសាសន៍ដទៃ។ ពួកជំនុំទាំង៧នៃ វិវរណៈ គឺជាពួកជំនុំសាសន៍ដទៃ ហើយពួកគេនិមួយៗឆ្លុះបញ្ចាំងពិអត្តចារិកជាក់លាក់ នៅក្នុងយុគសម័យនិមួយៗ។ យុគសម័យពួកជំនុំទាំង៧ គឺជាពេលវេលានៃដំណឹងល្អរបស់ព្រះគ្រីស្ទ ដល់ពួកសាសន៍ដទៃដើម្បីផ្សាំពួកគេទៅនឹងដើមអូលីវ។ នៅកំឡុងពេលនេះ ទ្បីបានទាយដោយពួកហោរាសញ្ញាចាស់ថា ជា*សេចក្តីអាថ៌កំបាំងនៃព្រះ*។ ជាញឹកញាប់ នៅក្នុងសញ្ញាថ្មី វាសំដៅទៅលើ *នគរស្ថានសួគ៌*។ (ចូរអាន វិវរណៈ ១០:៧, រ៉ូម ១១:១៧-២៥, ១៦:២៥, អភេសូរ ៣:៦, កាឡាទី ៣:១៦-១៨, លោកុប្បត្តិ ១២,១៥,១៧, អេសាយ ៤២:៦, ៤៩:៦, ៦០:៣)។

នៅ២កូរិនថូស ១១:២ បានថែងយ៉ាងច្បាស់ថា ពួកជំនុំព្រះគ្រីស្ទត្រូវបានដណ្តឹងថ្វាយព្រះយេស៊ូគ្រីស្ទ។ ប៉ូលគឺជាម្នាក់ នៃមិត្តសម្លាញ់ទាំង៧នៃព្រះបន្ទូលនៃព្រះ គាត់ត្រូវបានចាត់ឲ្យទៅឯពួកសាសន៍ដទៃ ដើម្បីយកកូនក្រមុំថ្វាយទ្រង់។ ហើយដោយសំរេចការនោះគាត់ក៏បានដណ្តឹងនាង ថ្វាយព្រះគ្រីស្ទ ទុកដូចជក្រមុំបរិសុទ្ធទាំងចិត្តទាំងកាយ រហូតដល់ថ្ងៃនៃពិធីរៀបការរបស់នាង (លោកុប្បត្តិ ២៩:២១, យ៉ូអែល ១:៨) ។ ប៉ុន្តែ ដោយដឹងថា សេចក្តីអាថ៌កំបាំងនៃការទុច្ចរិត បានចាប់ផ្តើមធ្វើការ ២ឬ៣ ឆ្នាំពីមុន (២ថែស្សាឡូនិច ២:៧) គាត់បានហាមពួកជំនុំ កុំឲ្យត្រូវគេដឹងនាំឲ្យវង្វេងចេញពី សភាពបរិសុទ្ធរបស់នាងឡើយ២កូរិន១១:៣,៤)។

បើសិនជាពួកជំនុំដើមដំបូង បាននៅស្មោះត្រង់ចំពោះ*ប្តី*-ជាព្រះអង្គសង្គ្រោះរបស់នាង ក្នុងកំឡុងពេលចូលស្តីដណ្តឹងនាង (ម៉ាកុស ១៤:២៣-២៥) នាងនឹងបាន***គ្រប់លក្ខណ៍*** ដែលមានការបើកសំដែងពេញលេញនៃព្រះគ្រីស្ទជាព្រះបន្ទូល និងបាននៅក្នុងការប្រកបជាមួយព្រះគ្រីស្ទ ជាប្តីរបស់នាង។ បន្ទាប់មក នាងបានចូលទៅ ***ពិធីលៀងវិវាហមង្គលកូនចៀម ។*** (បាទបើសិនជានាងគ្រាន់តែអនុញ្ញាតឲ្យផ្កាយព្រឹក យាងចូលមកក្នុងចិត្តរបស់នាង)។ ប៉ុន្តែដូចជាបានឆ្លុះបញ្ចាំងដោយសេចក្តីទំនាយនៅក្នុងការបញ្ឆោតអេវ៉ា នៅក្នុងសួនច្បារអេដែនមិនអាចទៅជាដូច្នេះទេ។ បន្ទាប់ពី អេវ៉ា ត្រូវបានដណ្តឹងទៅឲ្យអ័ដាម (លោកុប្បត្តិ ២:១៨,២១-២៤) មុននឹងប្តីរបស់នាងអាចចូលទៅឯនាង ក្នុងភាពជាប្តីប្រពន្ធនឹងគ្នា នាងបាន***ចាញ់បញ្ឆោត*** ដោយពស់ (សត្វដូចមនុស្ស) ហើយបានធ្វើឲ្យខ្លួន***ស្មោក គ្រោក*** ។

វិវាហមង្គលនៃកូនចៀម

ការស្រដៀងគ្នាមុនព្រះគ្រីស្ទអាចចាប់ផ្តើមស្គាល់ពួកជំនុំរបស់ទ្រង់យ៉ាស្និទ្ធស្នាល ដូចជាប្រពន្ធ នាងត្រូវបានខូចខ្លួនដោយវិញ្ញាណផ្សេងទៀត ដោយទទួលដំណឹងល្អផ្សេងទៀត នាងបានទៅជាពុករលួយក្នុងរយះពេលខ្លី បន្ទាប់ពី ប៉ូលបានហាមប្រាមនាង ។

## សេចក្តីស្រឡាញ់

អូ វានឹងទៅជារឿងខុសគ្នា បើសិនជាពួកជំនុំដើមដំបូងមានគំនិតផ្តោតទៅលើព្រះអង្គជាទីស្រឡាញ់របស់នាង ដូចជារេបិកាមានចំពោះអ៊ីសាក ។ ដោយបានឮយ៉ាងច្រើនពីអាលាសើរ អំពីអត្តចារិក និងបុគ្គលិកលក្ខណះរបស់អ៊ីសាក និងអំប្រាហាំ និងសេចក្តីស្រឡាញ់ពួកគេមានចំពោះព្រះ និងមនុស្ស រេបិកាមិនអាចធ្លាក់ក្នុងអន្លង់ស្នេហ៍នឹងអ៊ីសាកទេ។ ជាការពិត វាមិនមែនជាអំណោយដ៏ថ្លៃ ឬទ្រព្យ សម្បត្តិ ឬស្ថានភាពគ្រួសារអ័ប្រាហាំនោះទេដែលបណ្តាលឲ្យរេបិកា ត្រូវគេទិញនោះ ប៉ុន្តែគឺ ជាសេចក្តីស្រឡាញ់នៃ ឪពុករបស់អ៊ីសាក ដែលបានទាក់ទាញនាង (ដូចយ៉ាកុបមានចំពោះរ៉ាជែល លោកុប្បត្តិ ២៩:២០-២១)។ គឺគ្រាន់តែ១ថ្ងៃប៉ុណ្ណោះ ដែនាងត្រូវការឮ និងទទួលដំណឹងល្អនោះ។ នាងបានសំរេចចិត្តធ្វើជាប្រពន្ធរបស់អ៊ីសាក។ វាគឺជាជំរើសសាមញ្ញ, ទោះបីជាយ៉ាងណាក៏ដោយ ផ្លូវត្រឡប់ទៅហេប្រុន ក្នុងស្រុកកាណាន ពីក្រុងណាឃរ ក្នុងប៉ាដានអើរ៉ាម មិនមែនជាផ្លូវស្រួលទេ វាគឺជាដំណើរដ៏យូរ ។ ហើយវាជារឿងធម្មតាសំរាប់ស្ត្រី ចំពោះរឿងធ្វើដំណើរបែបនេះ ដែលមានការគិតជាច្រើនលិចលង់នៅក្នុងគំនិតរបស់នាង ។ ដូច្នេះ ទាល់តែនាងបានចូលទៅក្នុងភាពជាប្តីប្រពន្ធនឹងគ្នាជាមួយអ៊ីសាក ទើបរេបិកាអាចរកបានសេចក្តីដោះទុក្ខ នៅក្នុងពាក្យរបស់អេលាសើរ ។

តើពួកបរិសុទ្ធនៃពួកជំនុំដើមដំបូងដូចរេបិកាឬទេ? ម្ចាស់ថ្លៃអើយ! ទេ! ពួកគេមិនបានប្រយ័ត្ននឹងពាក្យរបស់ប៉ូលទេ នៅពេលដែលពួកគេធ្វើដំណើរឆ្លងកាត់ពិភពលោកដ៏អាក្រក់នោះ ។ ប៉ូលបានព្រមានពួកគេហើយ “ *តែខ្ញុំខ្លាចក្រែងគំនិតអ្នករាល់គ្នាត្រូវបង្ខូចចេញ ដូចជាសត្វពស់បានបញ្ឆោតនាងអេវ៉ា ដោយឧបាយកលយ៉ាងនោះដែរ ពីព្រោះបើសិនជាមាននរណាមក ប្រកាសប្រាប់ពីព្រះយេស៊ូ១ទៀត ដែលយើងខ្ញុំមិនបានប្រកាសប្រាប់ ឬបើអ្នករាល់គ្នាទទួលវិញ្ញាណណាផ្សេងទៀត ដែលមិនទទួលកាលពីដើម ឬដំណឹងណាផ្សេងទៀតដែលមិនទទួលកាលពីមុន នោះអ្នករាល់គ្នានឹងទ្រាំទ្រវិញជាមិនខាន ” (២កូរិនថូស ១១:៣-៤*។ ប៉ុន្តែពួកគេ*បានចាញ់ បញ្ឆោត* និង*ត្រូវបំផ្លាញ* ដោយឧបាយកលដ៏វាងវៃ និងគំរោងបញ្ឆោតរបស់ពូជសត្វពស់ (Serpent) សត្វដូចមនុស្ស)។

ដូច្នេះហើយ កូនក្រមុំ ដែលបានដណ្តឹងហើយ របស់ព្រះគ្រីស្ទ ត្រូវបង្ហូច គឺមុននឹងនាងរៀបការនឹងទ្រង់ទៀត។ ពិធីរៀបការត្រូវតែ*រៀបចំធ្វើនៅពេលក្រោយ* ពីព្រោះកូនក្រមុំ*មិនទាន់រៀបខ្លួន* ជាស្រេច សំរាប់រៀបការទេ ។ *សំលៀកបំពាក់រៀបការ* ***នៃសេចក្តីសង្គ្រោះ*** របស់នាងបាន*ប្រឡាក់* និង***មានកន្លែងបន្ទោសបាន*** ។ ប៉ុន្តែព្រះបានដកនាងចេញពីសភាព នៃការស្មោកគ្រោក និងទុកឲ្យនាងឆ្លងកាត់កំឡុងពេលសំរងឲ្យស្អាត ដើម្បីស្តារនាងទៅឯ សភាពដើមវិញ។

## ការប្រារព្ធពិធីរៀបការ

ពិធីរៀបការនៃជនជាតិខាងផ្នែកអាស៊ី ផ្សេងៗគ្នាជាច្រើន ដូចជាពួកអារ៉ាប់ ឥណ្ឌា និងចិន គឺគេធ្វើឡើង***យ៉ាងធំដុំណាស់*** ។ ពួកគេជាច្រើនបានធ្វើឡើងតាំងពីសម័យ***គម្ពីរ*** ម្លេះ ។ មាន***ព្រឹត្តិការណ៍នៃការប្រារព្ធជាច្រើន*** ប៉ុន្តែមិនមែនទាំងអស់ដែលចាំបាច់ឲ្យយើងអង្កេតទេ នៅក្នុងពិធីរៀបការទាំងអស់នោះទេ ។ លក្ខណៈពិសេស***ដ៏សំខាន់*** នៃការប្រារព្ធជាច្រើន គឺ***ការប្រកាសជាសាធារណៈ*** នៃទំនាក់ទំនងរវាងប្តីប្រពន្ធ។ ទំនាក់ទំនងខាងវិញ្ញាណរវាងព្រះគ្រីស្ទ នឹងកូនក្រមុំរបស់ទ្រង់ បានឆ្លុះបញ្ចាំងឲ្យឃើញ នៅក្នុងដំណើរការពិធីរៀបការទាំងមូល។ បាទ កិច្ចការខាងស្នេហានៃគូដែលដណ្តឹងហើយ ត្រូវតែធ្វើឲ្យសាធារណៈជនបានដឹងឮ។ គឺនៅក្នុងពិធីរៀបការ ដែលគូនេះ ***ត្រូវបង្ហាញដល់***លោកីយ៍ជាបុរស និងប្រពន្ធ។

## ការមុជទឹក ដែលរៀបចំទុក ដ៏ពិសេស

"*ភាពស្អាត គឺនៅក្បែរភាពបរិសុទ្ធដូចព្រះ*" ជាសេចក្តីដែលគេនិយាយដូច្នេះ។ មនុស្សមុជទឹក គឺជាការអនុវត្តប្រចាំថ្ងៃ ហើយជាពិសេស នៅពេលដែលពួកគេកខ្វក់ ឬពេលពួកគេធុំក្លិនមិនល្អ។ គ្មានមនុស្សត្រឹមត្រូវណា នឹងស្លៀកសំលៀកបំពាក់ស្អាត អន់ជាងសម្លៀកបំពាក់រៀបការទេ បើសិនជាខ្លួនម្នាក់នោះកខ្វក់ និងធុំក្លិនអាក្រក់។ នៅផ្នែកខាងអាស៊ី មានការមុជទឹកជាក់លាក់ ដែលធ្វើឡើងនៅពេលមាន***ឱកាសពិសេសៗជាក់លាក់***ប៉ុណ្ណោះ ។ ជាធម្មតា ពួកគេត្រូវបានយកជា ***ក្បួនហែរនៃការសំអាត*** ។ ហើយក្នុងឱកាសបែបនេះ គឺជាពីធីរៀបការ ។

គឺគ្រាន់តែមុនពិធីរៀបការ កូនកំលោះ និងកូនក្រមុំ នឹងមុជទឹកពិសេស នៅក្នុងផ្ទះដែលជាទីគោរព ។ (ពួកយូដាមានអ្វី ដែលគេហៅថា មិកវ៉ា(mikvah)មុជទឹកនៅក្នុងទឹកហូរ)។ ពួកគេមិនគ្រាន់តែចង់ឲ្យខ្លួនពួកគេបានស្អាតផូរផង់ប៉ុណ្ណោះទេ ប៉ុន្តែក៏ធុំក្លិន និងដឹងថា ស្អាតដែរ ពីព្រោះក្លិនខ្លួនអាក្រក់ និងញើសធុំក្លិនជូរ ធ្វើឲ្យ ***អាក់អន់ចិត្តណាស់***។ ក្លិនអាចងាយនឹងជ្រាបចូលសម្លៀកបំពាក់ណាស់។ ដូច្នេះទឹកអប់ និងរុក្ខជាតិក្រអូប ត្រូវបានបន្ថែមចូលទៅក្នុងអាងទឹក។ បន្ទាត់ពីមុជ

ទឹកហើយ ពួកគេនឹងចាក់ប្រេងដ៏មានតម្លៃពិសេសៗ លាបលើខ្លួនពួកគេ។ មុននឹងពួកគេស្លៀកសំលៀកបំពាក់រៀបការរបស់ពួកគេ។

ព្រះអម្ចាស់យេ ស៊ូគ្រីស្ទបាន មុជទឹកពិសេសរបស់ទ្រង់ មុនពេលទ្រង់ចាប់ផ្តើមព័ន្ធកិច្ច របស់ ទ្រង់ដើម្បី ស្វែងរកកូនក្រមុំសំរាប់ទ្រង់ផ្ទាល់។ ទ្រង់បានស្អាតដោយសារទឹកហូរនៃទន្លេយ័ដាន់ និងបន្ទាប់មក បានទទួលប្រេងតាំងដោយព្រះវិញ្ញាណ ដែលមានក្លិនក្រអូបរបស់ព្រះ នៅលើទ្រង់ (ម៉ាថាយ៣ : ១៦-១៧)។ ហើយបុគ្គលិកលក្ខណៈរបស់ទ្រង់បញ្ចេញរសជាតិ ផ្អែមពីស្ថានសួគ៌។

---

ម៉ាយថាយជំពូក ៣

*១៦ កាលព្រះយេស៊ូ បានទទួលបុណ្យជ្រមុជទឹកហើយ នោះទ្រង់យាងឡើងពីទឹកភ្លាម ស្រាប់តែមេឃក៏បើកឡើង ឲ្យទ្រង់ឃើញព្រះវិញ្ញាណបរិសុទ្ធនៃព្រះ យាងចុះមកដូចជាសត្វព្រាប ក៏សណ្ឋិតលើទ្រង់។*

*១៧ នោះមានឮសំលេងចេញពីមេឃថា នេះជាកូនស្ងួនភ្ងា របស់អញ ជាទីពេញចិត្ត អញណាស់។*

---

ប៉ុន្តែតើសម្លៀកបំពាក់ប្រភេទណា ដែលព្រះ យេស៊ូទ្រង់ព្រះពស្ត្រ បន្ទាប់ពីមុជទឹករួច? ជាការពិត គឺព្រះបន្ទូលនៃព្រះ។ បទគម្ពីរបានចែងថា នៅពេលទ្រង់ត្រូវសេចក្តីល្បួងរបស់ងារក្ស នៅទីរហោស្ថាន ទ្រង់បានឈ្នះវាដោយសារព្រះបន្ទូលនៃព្រះ។ ទ្រង់បានព្រះពស្ត្រដោយសម្លៀកបំពាក់នៃព្រះបន្ទូលដែលចែងទុក៣ដង ***"បានចែងទុកថា! បានចែងទុកថា! បានចែងទុកថា!"*** (ម៉ាថាយ៤:១-១៤)។អាម៉ែន (ដោយនិយាយព្រះបន្ទូល ដែលផ្អែកលើការបើកសំដែងនៃព្រះបន្ទូលដ៏ពិសិដ្ឋ ព្រះរាជបុត្រានៃព្រះ គឺព្រះយេស៊ូគ្រីស្ទ បានឈ្នះខ្មាំងសត្រូវនៃព្រះ)។ ព្រះគ្រីស្ទយេស៊ូទ្រង់ផ្ទាល់ជាព្រះ គឺជា សំលៀកបំពាក់ពិត ដែលបានប្រទាន ដល់កូនក្រមុំរើសតាំងរបស់ទ្រង់។ គឺបានប្រទានដល់នាង ទុកជាប្រដាប់ សំរាប់ទទូរសំរាប់ព្រលឹងវិញ្ញាណដ៏ដូចជាសំលៀកបំពាក់ រៀបការដែរ-សំលៀកបំពាក់ នៃសេចក្តីសង្គ្រោះ (មើល អេសាយ ៦១:១០, អេភេសូរ ៦:១១-១៨)។

ការមុជទឹកពិសេសរបស់កូនក្រមុំព្រះគ្រីស្ទ មានបីដំណាក់កាល។ ហើយវាដូចជាព្រះវិញ្ញាណនៃព្រះ ដែលដឹកនាំនាង ឆ្លងគ្រប់ដំណាក់កាលដែរ។ ដំណាក់ទី១ នាងមុជទឹកក្នុងឈាម។ នាងត្រូវតែបានស្អាតដោយសារឈាមកូនចៀមនៃព្រះជាប្តីនៃសេសក្តីសង្គ្រោះរបស់នាង គឺព្រះគ្រីស្ទយេស៊ូ ដែលបានទិញនាង ដោយតម្លៃឈាមរបស់ទ្រង់នៅកាល់វ៉ារី។ ដូច្នេះ នេះគឺជាជំហានដ៏ឧឡារិក និងសំខាន់ជាងគេបំផុត។ បើគ្មានការរាប់ជា សុចរិត ដោយឈាម របស់ទ្រង់ បាបរបស់នាង

នឹងនៅជាប់ដដែល ហើយនាងនឹងមិនបានស្អាតទេ។ (រ៉ូម ៥:៩, ហេព្រើរ ៩:២២, ១០:១៤)។ គឺជាឈាមដដែល ដែលថែរក្សានូវលក្ខណៈ***នៃអំពើបាបដើម*** ដែលនាងមានជាមរតកតាំងពីការធ្លាក់ចុះក្នុងអំពើបាបនោះម្ល៉េះ(ហេព្រើរ ១០:១៥-១៨) កូនក្រមុំព្រះគ្រីស្ទ មិនមែនបានទិញដោយដំណោយដ៏វិសេស ដែលព្រះវរបិតាបានប្រទានដល់ព្រះគ្រីស្ទទេ។ នាងត្រូវបាន ***"ទិញដោយឈាមរបស់ទ្រង់ផ្ទាល់"*** (កិច្ចការ ២០:២៨)ដែលជាចំណងដៃរបស់ទ្រង់។ សេចក្តីស្រឡាញ់របស់ទ្រង់បានធ្វើការនេះ។ អាម៉ែន!

ពិធីជ្រមុជទឹក គឺជាពិធីមុជទឹកបន្ទាប់ ដែលបាបជាច្រើន ដែលនាងបានប្រព្រឹត្ត ត្រូវបានលុបចោលចេញ។ ផ្លូវត្រឹមត្រូវ***ដែលមានតែ១គត់*** សំរាប់នាង ដើម្បីមុជទឹកនេះ គឺត្រូវធ្វើវាយោងទៅតាមកិច្ចការ ២:៣៨។ នេះគឺជាផ្លូវ ដែលដឹកនាំដោយព្រះវរបិតា ដែលគង់នៅស្ថានសួគ៌។ ការមុជទឹក***សំគាល់ថា*** នាងជានរណា នាងត្រូវតែទទួលការនេះ ដោយការកប់ចូលទៅផ្លូវទឹក នៅក្នុងព្រះនាមវិសេសនៃព្រះអម្ចាស់យេស៊ូគ្រីស្ទ(ប្តីរបស់នាង)។ គ្មានផ្លូវឬព្រះនាមណា ដែលអាចទទួលយកបានទេ។ បើសិនជានាងពិតជាស្រឡាញ់ទ្រង់អស់អំពីចិត្ត គំនិត រូបកាយ និងវិញ្ញាណ និងពិតជាផ្លាស់ប្រែដោយព្រះវិញ្ញាណ នោះនាងបានប្រដាប់កាយដោយព្រះគ្រីស្ទ ដូចជាប៉ូលបាននិយាយថាៈ *"ពីព្រោះអស់អ្នកណា ដែលបានទទួលបុណ្យជ្រមុជក្នុងព្រះគ្រីស្ទ នោះឈ្មោះថា បានប្រដាប់កាយដោយព្រះគ្រីស្ទហើយ"(កាឡាទី៣:២៧)*។ត្រឹមត្រូវហើយ!គ្រប់កូនក្រមុំត្រូវមានឈ្មោះ**ប្តីរបស់នាង!**

*"ប្តីរាល់គ្នាអើយ ចូរស្រឡាញ់ប្រពន្ធខ្លួន ដូចជាព្រះគ្រីស្ទបានស្រឡាញ់ដល់ពួកជំនុំ ហើយបានប្រគល់ព្រះអង្គទ្រង់ជំនួសផង ដើម្បីឲ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសំអាតនឹងទឹក គឺជាព្រះបន្ទូល ប្រយោជន៍នឹងថ្វាយពួកជំនុំនេះដល់ព្រះអង្គទ្រង់ទុកជាពួកជំនុំដ៏ឧត្តម ឥតប្រឡាក់ ឥតជ្រួញ ឬមានអ្វីឲ្យដូចឡើយ គឺ ឲ្យបាន បរិសុទ្ធ ហើយ ឥតកន្លែង បន្ទោសបានវិញ" អេភេសូរ ៥:២៥-២៧)*

នេះគឺជាដំណាក់កាលទី៣នៃការមុជទឹក *"ដោយបានសំអាតដោយទឹក ជាព្រះបន្ទូលនៃព្រះ"*។ ការនេះបានបញ្ចប់ការសំអាតជាការប្រា រព្ធពិធីទាំងមូលសំរាប់កូនក្រមុំ។ មិនដូចជាដំណាក់កាលទី២ដូបូងនៃការមុជទឹកទេ ដែលសំអាតនាងពី**អំពើបាបដើម** និង**សកិយាបទនៃអំពើបាប** ការមុជទឹកដោយ ព្រះបន្ទូល គឺជាដំណើរការនៃការ**លាងសំអាតតៗ គ្នាសំរាប់វិញ្ញាណ** នៃកូនក្រមុំ (ដើម្បីរក្សានាងឲ្យរួចផុតពីសេចក្តីបង្រៀន និងការគិតខុសឆ្គង លក្ខណៈបញ្ឆោត និងអំពើខាងសាច់ឈាម-ការមិនស្រុះស្រួលគ្នា ការឥតកោតក្រែង អាត្មានិយម ការច្រណែន កំហឹង

ភ័យខ្លាច ភាពមិនយកចិត្តទុកដាក់ ភាពក្រអឺតក្រទម **អំនួត** ។ល។)ដែលនាងត្រូវ *"រៀបខ្លួនជាស្រេច"* សំរាប់ *"ពិធីលៀងវិវាហមង្គលនៃកូនចៀម"។* បន្ទាប់មក និង មានតែបន្ទាប់មកទេ ដែលនាងនឹងត្រូវបានប្រទានឲ្យស្លៀកពាក់សំពត់ទេស យ៉ាង ម៉ដ្ឋ ស្អាត ហើយភ្លឺ ដែលជា *រ៉ូបនៃសេចក្ដីសុចរិត របស់នាង។* ដើម្បីបំពាក់ឲ្យនាង ក្នុងសំលៀកបំពាក់ស មុននឹងនាងបានរៀបខ្លួនជាស្រេច គឺពិតជាមិនអាចគិត ដល់ទេ ពីព្រោះការស្លៀកពាក់សំលៀកបំពាក់នោះ គឺជាទីបន្ទាល់ ចំពោះស្មរ បន្ទាល់ទាំងអស់ នៅឯពិធីលៀងវិវាហមង្គល ដែលនាងត្រូវ បានតាំងឡើងឲ្យមាន តំណែងជាស្ត្រី ដែលព្រះគ្រីស្ទបានស្គាល់យ៉ាងស្និទ្ធស្នាល ថាជាប្រពន្ធរបស់ទ្រង់ នៅថ្ងៃរៀបអាពាហ៍ពិពាហ៍។ ដូច្នេះ សំលៀកបំពាក់នោះ មិនអាចពាក់បានទេ ទាល់តែនាងបានបញ្ជាក់ដោយខ្លួននាងថា សក្តិសមនឹងធ្វើជា ភិរិយារបស់ទ្រង់។

## សំលៀកបំពាក់រៀបការ

គួរឲ្យភ្ញាក់ផ្អើលមែន ពួកគ្រីស្ទកំរបានស្គាល់ថានៅក្នុងការ រៀបវិវាហមង្គលខាងផ្នែកអាស៊ីពី បុរាណភាគច្រើន គេឲ្យកូនក្រមុំមាន សំលៀកបំពាក់រៀបការ២ប្រភេទ។

ពួកគ្រីស្ទតែងតែប្រដូចសំលៀកបំពាក់ រៀបការរបស់កូនក្រមុំជាមួយពណ៌ស។ នេះគឺ ដោយសារពណ៌ស មានទំនាក់ទំនងនឹង ***ភាពបរិសុទ្ធ*** និង ***ការវិសុទ្ធ*** នៅក្នុងបទគម្ពីរ។ ដូច្នេះ កូនក្រមុំក្នុងសំលៀកបំពាក់ស គឺមានរូបភាព ដូចជាស្ត្រី បរិសុទ្ធ និង ស្អាត ដែលត្រៀមខ្លួនជាស្រេច ដើម្បីនឹងបង្ហាញដល់បុរស នោះ នៅថ្ងៃរៀបការ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការរៀបការផ្នែកខាង អាស៊ីពិតជាច្រើន **សំលៀកបំពាក់ ពណ៌ភ្លឺ**មានលក្ខណៈទូទៅជាង។ ទ្រព្យសម្បត្តិ ភាគច្រើន គឺជាព្រះភូសាប៉ាក់ ធ្វើអំពីសំពត់ទេសយ៉ាងម៉ដ្ឋ(មើលទំនុកដំកើន ៤៥: ១៣-១៤)។ គួរឲ្យភ្ញាក់មែន ពួកគ្រីស្ទកំរបានស្គាល់ថា នៅក្នុងការរៀបវិវាហមង្គល ខាងផ្នែកអាស៊ីពីបុរាណភាគច្រើន គេឲ្យកូនក្រមុំ មានសំលៀកបំពាក់រៀបការ២ ប្រភេទ។ ពួកវាអាចជាគំរូខាង

វិញ្ញាណ គឺ *"សំលៀកបំពាក់នៃសេចក្តីសង្គ្រោះ"* និង *"អាវ(រ៉ូប)នៃសេចក្តីសុចរិត"។* ការនេះគឺនិយាយដោយហោរាអេសាយ(ជំពូក៦១ ខ១០):

*ខ្ញុំនឹងអរសប្បាយចំពោះព្រះយេហូវ៉ា ព្រលឹងខ្ញុំនឹងរីករាយចំពោះព្រះនៃខ្ញុំពី ព្រោះទ្រង់បានប្រដាប់ខ្លួនខ្ញុំ ដោយសំលៀកបំពាក់នៃសេចក្តីសង្គ្រោះ និងបានគ្រលុំ ខ្ញុំដោយអាវនៃសេចក្តីសុចរិត ដូចជាប្តីថ្មោងថ្មី តែងខ្លួនដោយគ្រឿងលំអ ហើយដូច ជាប្រពន្ធថ្មោងថ្មី ក៏ប្រដាប់ដោយត្បូងរបស់ខ្លួនដែរ។*

នៅពេលដែលអ្នកបំរើអ័ប្រាហាំបានទៅឯណាឃរ ក្នុងស្រុកអើរ៉ាម(មេសូប៉ូតាមា)ដើម្បីទៅទទួលកូនក្រមុំឲ្យអ៊ីសាក គាត់បានយកគ្រឿងអលង្ការប្រាក់ និងមាសហើយនិងប្រដាប់ប្រដារស្លៀកពាក់សំរាប់កូនក្រមុំ។ ទាំងនោះគឺជាអំណោយសំរាប់កូនក្រមុំ ដែលរេបិកាត្រូវតែទទួលយក បើសិនជានាងមានសេចក្តីប្រាថ្នាចង់ធ្វើជាប្រពន្ធអ៊ីសាក។ ក្នុងចំណោមអំណោយដ៏វិសេសៗ សំលៀកបំពាក់កូនក្រមុំប្រហែលជាត្បាញ និងប៉ាក់ដ៏ស្អាត ប៉ុន្តែ **មិនមែនធ្វើអំពីក្រណាត់ទំនើបទេ។** ពាក្យហេព្រើរ ដែលប្រើ(សំរាប់សំលៀកបំពាក់ក្នុងលោកុប្បត្តិ ២៤ : ៥៣) គឺប៊ីជិត (Beged)។ ពាក្យដដែលនេះត្រូវបានបកប្រែថា សំលៀកបំពាក់ នៅក្នុង អេសាយ ៦១:១០-*"សំលៀកបំពាក់នៃសេចក្តីសង្គ្រោះ"។* យោងតាមគម្ពីរវិវរណៈ ពួកយូដាស្មោះត្រង់ និងពួកបរិសុទ្ធឆ្លងកាត់គ្រាវេទនា (វិវរណៈ៦:១១, ៧:៩-១៤)អ្នកទាំង២នេះស្លៀកពាក់រ៉ូប(ពាក្យក្រិកៈស្តូល[stole])ពណ៌សដ៏ឧត្តុង្គឧត្តម។ ទោះយ៉ាងណាក៏ដោយ កូនក្រមុំនៃព្រះគ្រីស្ទ(វិវរណៈ ១៩:៧-៨)ទ្រង់បានប្រទានឲ្យសំពត់ទេសយ៉ាងម៉ដ្ឋ ស្អាត ហើយស។ សំលៀកបំពាក់នេះមិនគ្រាន់តែថ្លៃ និងឧត្តុង្គឧត្តមប៉ុណ្ណោះទេ ប៉ុន្តែភ្លឺចាំងខ្លាំងមែនទែន(មើល លូកា ៩:២៩)។ ពាក្យក្រិក ដែលពិពណ៌នាពីសំលៀកបំពាក់ល្អអស្ចារ្យនេះ គឺ *ហីម៉ាទីសម៉ូស*(himatismos)។ ពួកចាស់ទុំទាំង២៤នាក់(ក្នុងវិវរណៈ ៤:៤)ស្លៀកសំលៀកបំពាក់ធ្វើពីក្រណាត់នោះឯង(តើអ្នកបានសំគាល់ពីការពិពណ៌នារបស់ព្រះពស្ត្រហ្លួង និងការតែងកាយនៃប្រពន្ធជាកូនក្រមុំរបស់ព្រះយេហូវ៉ា និងរបស់អារក្សផងដែរឬទេ? **អេសេគាល ១៦** កត់ត្រាពីរបៀប ដែលព្រះយេហូវ៉ាបានរៀបវិវាហមង្គលជាមួយអ៊ីស្រាអែល និងតាំងនាងជាម្ចាស់ក្សត្រីយ៍ ហើយបានបំពាក់ឲ្យនាងនូវរបស់ស្អាត និងមានតំលៃវិសេស *"អាថ៌កំបាំង ក្រុងបាប៊ីឡូនដ៏ធំ"*ដែលអង្គុយជាម្ចាស់ក្សត្រីយ៍ គឺជាប្រពន្ធរបស់អារក្សជាមួយនឹងកូនស្រីជាច្រើនរបស់ស្រីសំផឹង។ នាងក៏តែងខ្លួនដោយរបស់ដ៏វិសេសៗ និងបំពាក់ដោយសំពត់ទេសយ៉ាងម៉ដ្ឋ។ ប៉ុន្តែ*សំលៀកបំពាក់សំពត់ទេស យ៉ាងម៉ដ្ឋ*របស់នាង ពិតជាមិនស្អាត និងសទេ។ នេះគឺជា*ពណ៌ស្វាយ* ហើយ*ក្រហម* ដែលបង្ហាញថា នាងជាម្ចាស់ក្សត្រីយ៍ដែលប្រឡាក់ឈាម និងជាប្រពន្ធ របស់អារក្ស(វិវរណៈ ១៧:៤, ១៨:១៦)។

## កំឡុងពេលរៀបការ

**ខ្ញុំចង់ឲ្យអ្នកចាប់អារម្មណ៍អំពី***ទំនៀមទំលាប់ និងប្រពៃណី* រៀបការ របស់ពួកអាស៊ីម្តងទៀត។ ដូចយើងបានដឹងហើយ អាពាហ៍ពិពាហ៍របស់ពួកខាងលិច ឬបស្ចិម ជាធម្មតាធ្វើឡើងមិនមានភាពអធឹកអធមទេ។ នៅថ្ងៃរៀបការ គូស្វាមីភរិយានឹងមុជទឹក និងស្លៀកសំលៀកបំពាក់រៀបការពួកគេ។ បន្ទាប់មក កូន

កំលោះនឹងបន្តទៅផ្ទះកូនក្រមុំ ដើម្បីយកនាងទៅវិហារ ឬទៅវិហារផ្ទាល់ និងរង់ចាំកូនក្រមុំនៅទីនោះ។ បន្ទាប់មកពួកគេនឹងត្រូវបានអ្នកមង្គលការរៀបការឲ្យ។ បន្ទាប់មកទៀត ក៏មានការទទួលទានអាហារ ឬជប់លៀងតិចតួច សំរាប់ភ្ញៀវដែលគេអញ្ជើញមក។ ជាធម្មតា ការនេះបញ្ចាប់ក្នុងពេលខ្លី ប៉ុណ្ណោះ មុននឹងគូស្វាមីភរិយាចេញទៅជិះឡានយ៉ាងប្រញាប់ សំរាប់រាត្រីចន្ទ្រាទឹកឃ្មុំរបស់ពួកគេ។

អ្នកនឹងកត់សំគាល់ថា ពិធីរៀបការទាំងមូល ជាធម្មតាបានបញ្ចាប់នៅពេលខ្លី ដែលចាប់ផ្តើមនៅពេលព្រឹក និងបញ្ចាប់នៅមុនពេលល្ងាច ហើយកូនក្រមុំគ្រាន់តែមានសំលៀកបំពាក់ការមួយសំរាប់ប៉ុណ្ណោះ ដែលជាសំលៀកបំពាក់វែងពណ៌សរបស់នាង។ ប៉ុន្តែអាពាហ៍ពិពាហ៍ផ្នែកខាងអាស៊ីបញ្ចាប់យ៉ាងហោចណាស់ក៏ពេញមួយថ្ងៃដែរ ចាប់ផ្តើមពីព្រឹករហូតដល់យប់។ ផ្អែកលើការឈរលើសង្គម ពួកអ្នកមាននឹងប្រារព្ធពិធីរៀបការអស់ បួនប្រាំថ្ងៃ ឬអាចឡើងដល់២សប្តាហ៍។

## សេចក្តីសង្គ្រោះ និងសេចក្តីសុចរិត

ដូច្នេះ ដូចជាបាននិយាយពីមុន កូនក្រមុំផ្នែកខាងអាស៊ី យ៉ាងហោចណាស់ក៏មានសំលៀកបំពាក់រៀបការ២ឈុតដែរ។ មួយពាក់(បន្ទាប់ពីមុជទឹកជម្រះកាយ) នៅពេលប្រារព្ធពិធីផ្សេងៗ-ពិធីហែរកូនកំលោះក្រមុំ ការប្រារព្ធ ពិធីឧឡារិកពិធីជប់លៀងធំ បន្ទាប់ពិសេសនិងពិធីផ្សេងៗទៀត។ មួយទៀត ពាក់នៅពេលពិធីលៀងវិវាហមង្គលដ៏ធំ និងចុងក្រោយ។ ដូច្នេះ វាជារឿងសំខាន់ ដែលយើងត្រូវចំណាំរឿងពិត ដែលកូនរបស់ព្រះ ដែលកើតជាថ្មីមាន***សំលៀកបំពាក់ស*** (១ឈុត) ***នៃសេចក្តី សង្គ្រោះ*** (មើល អេភេសូរ ៦:១១-១៨)។ វាជាបន្ទាល់ថា គាត់/នាង បានរាប់ជាសុចរិត ដោយសារជំនឿរបស់គាត់/នាង នៅក្នុងកិច្ចការប្រោះលោះរបស់ព្រះ ផ្អែកលើការបើកសំដែងមកពីព្រះនៃព្រះបន្ទូលរបស់ព្រះ។ (មើលវិវរណៈ ៧:៩, ១៣, ១៤,មើលជំពូក ៦:១១)។ ប៉ុន្តែមិនមែនគ្រប់គ្នានឹងបានពាក់***អាវ(រ៉ូប)ស នៃសេចក្តី សុចរិតទេ*** ទាល់តែគាត់/នាងបានបញ្ជាក់ដោយខ្លួនគាត់/នាងថាសក្តិសមនឹងទទួលវា**(មើល វិវរណៈ ៣:៥,១៨ មើលជំពូក ៤:៤)**។

[សំគាល់: **សេចក្តីសុចរិតមិន**មែនជាមូលដ្ឋានគ្រឹះនៃសេចក្តីសង្គ្រោះទេ(រ៉ូម ៥:៦-៩)ប៉ុ**ន្តែជាដំណាក់កាលតាមធម្ម**ជាតិនៃសេចក្តីសង្គ្រោះ។ មនុស្សម្នាក់ ដែលកើតជាថ្មីអំពីព្រះបន្ទូល និងព្រះវិញ្ញាណត្រូវបានរាប់ជាសុចរិត និងត្រូវបានសន្មត់ថា សុចរិតដោយព្រះអង្គសង្គ្រោះ(រ៉ូម ៤:១-៥)។ ប៉ុន្តែសេចក្តីសុចរិតមានន័យថា អ្វីត្រឹមត្រូវជាមូលដ្ឋាន។ ដូច្នេះនៅពេលដែលគ្រីស្ទាននៅក្នុងទំនាក់ទំនងខាងជំនឿជាមួយព្រះគ្រីស្ទ គាត់ត្រូវតែបែរចេញពីទាសករនៃអំពើបាប មកជាអ្នកបំរើនៃសេច

ក្តីសុចរិត(រ៉ូម ៦:១៦-២២, ម៉ាថាយ ៣:១៥)គាត់ត្រូវតែមានជំនឿ ដែលប្រព្រឹត្ត និងដែលបង្ហាញនូវសេចក្តីសុចរិតនៃជំនឿ(យ៉ាកុប ២:១៤-២៦)។ គាត់ត្រូវតែរស់ដោយសុចរិត ដើម្បីបញ្ជាក់ថា គាត់បានទទួលការរាប់ជាសុចរិតដោយសេចក្តីជំនឿក្នុងព្រះគ្រីស្ទ។ ដូច្នេះ គាត់ ដែលបានសង្គ្រោះ ត្រូវតែរស់នៅដូចដែលបានសង្គ្រោះហើយ។ អ្នកបរិសុទ្ធម្នាក់ ដែលគេឃើញថា *(កំពុងរស់ក្នុងព្រះបន្ទូលហើយ មិនគ្រាន់តែជឿព្រះបន្ទូលប៉ុណ្ណោះ គឺជាអំណរដល់ព្រះអម្ចាស់)*]

## សេចក្តីអាថ៌កំបាំង

សេចក្តីអាថ៌កំបាំងនៃព្រះគ្រីស្ទ និងពួកជំនុំរបស់ទ្រង់(អេភេសូរ ៥:៣២)អាចយល់ច្បាស់បាន ដោយមើលទៅ***ពិធីប្រារព្ធអាពាហ៍ពិពាហ៍ផ្នែកខាងអាស៊ីសម័យបុរាណ*** ដែលភាគច្រើននៅតែយកមកអនុវត្តសព្វថ្ងៃនេះដែរ។ ពួកយូដាភាគច្រើនកំនត់***៧ថ្ងៃ***សំរាប់រៀបការ(សូម្បីតែការចូលស្តីដណ្តឹងក៏ចំណាយអស់ច្រើនថ្ងៃដែរ)។ ការរៀបការ៧ថ្ងៃ នេះគឺជាការអនុវត្តតាំងពីសម័យសញ្ញាចាស់ម្ល៉េះ។ (លោកុប្ប២៩ ពួកចៅហ្វាយ ១៤)។ ខាងឯទំនាយ ***៧ថ្ងៃ*** ជា***គំរូ យុគសម័យពួកជំនុំទាំង៧។***

## យុគសម័យពួកជំនុំទាំង៧

ជិត២ពាន់ឆ្នាំមកហើយ ដែលព្រះរាជបុត្រានៃព្រះបានយាងមកពីដំណាក់ដ៏សែនឆ្ងាយរបស់ទ្រង់ក្នុងសិរីល្អ ដើម្បីស្វែករក**ភរិយា** ពីក្នុងចំណោមរាស្ត្ររើសតាំងផ្ទាល់របស់ទ្រង់ គឺអ៊ីស្រាអែល។ ប៉ុន្តែពួកគេមិនស្គាល់ថា ទ្រង់ជា***ម្ចាស់ស្នេហ៍***របស់ពួកគេទេ ហើយពួកគេបានបដិសេធទ្រង់ និងបានឆ្កាងទ្រង់។ សូម្បីតែ***អ្នករៀបផ្លូវ*** និងជា***មិត្តសម្លាញ់*** របស់ទ្រង់ យ៉ូហាន-បាទីស្ទ ក៏ត្រូវគេចំអកឲ្យ និងត្រូវគេកាត់ក្បាលផងដែរ។ ហេតុនេះហើយ ព្រះរាជបុត្រាដ៏មានសិរីល្អនៃព្រះដែលគង់នៅខាងស្តាំព្រះហស្តនៃព្រះវរបិតារបស់ទ្រង់ បានបែរទៅយកពួកសាសន៍ដទៃ មកធ្វើជាភរិយាវិញ។ ទ្រង់បានធ្វើការនេះមិនយូរប៉ុន្មានទេ បន្ទាប់ពីទ្រង់បានចាក់ព្រះវិញ្ញាណរបស់ទ្រងមកលើ**ពួកយូដា** ដែលកើតជាថ្មីពីរបីពាន់នាក់ ដែលបានទទួលយកដំណឹងល្អ។ ហើយ***អ្នកបរិសុទ្ធ ប៉ុល*** ដូចយើងដឹងហើយ គឺជា***អ្នកទី១*** នៃ***មិត្ត សម្លាញ់ទាំង៧*** ដែលទ្រង់បានចាត់ឲ្យទៅទាក់ទង ជាមួយកូនក្រមុំសាសន៍ដទៃ។

អញ្ជឹង ដោយជំនួសឲ្យការរក្សាគំនិតរបស់នាងលើព្រះបន្ទូល និងបានសំអាតដោយព្រះបន្ទូលយ៉ាងហ្មត់ចត់ កូនក្រមុំដែលបានដណ្តឹងហើយរបស់ព្រះគ្រីស្ទបានពាក់សំលៀកបំពាក់រៀបការនៃសេចក្តីសង្គ្រោះ ដែលប្រឡាក់ដោយគោលលទ្ធិខុសឆ្គងរបស់សាតាំង និងក្រុមវិញ្ញាណអាក្រក់។ ដូច្នេះ ***ប្តី***ជាអ្នកសង្គ្រោះ

របស់នាង ត្រូវតែពន្យាពេលវិវាហមង្គល ព្រោះនាងបានបោះបង់សេចក្ដីស្រឡាញ់ដើម ហើយបន្ទាប់មក ត្រូវឆ្លងកាត់ការជម្រះសំអាត។ មិនមានវិវាហមង្គលឡើយ ទាល់តែ នាងបានរៀបខ្លួនពេញលេញជាកូនក្រមុំហើយសិន។ ដូច្នេះ ថ្ងៃទី១ *(សម័យពួកជំនុំទី១-វិវរណៈ ២:១-៧)*បានមកដល់ និងកន្លងបាត់ហើយ។ ទោះជានាងនៅអត់ធ្មត់ ថ្ងៃទី២*(សម័យពួកជំនុំទី២-វិវរណៈ ២:៨-១១)*គឺជាការចាប់ផ្ដើមនៃគ្រាវេទនា និងការសាកល្បង។ វាគឺជាកុំឡុងពេលនៃការល្មីងជូរចត់។ ***អ៉ីរីណើស*** គឺជា **អ្នកនាំព្រះរាជសារ-*អ្នកបំរើទី២*** ដែលព្រះគ្រីស្ទបានចាត់មកឯនាង។ ព្រះរាជសាររបស់គាត់អាចឲ្យនាងឈរទ្រាំទ្រនឹង ***ការបៀតបៀន*** ពីពួកជំនុំអារក្សសាតាំង

នៅថ្ងៃទី៣*(សម័យពួកជំនុំទី៣-វិវរណៈ ២:១២-១៧)**សំលៀកបំពាក់*** របស់នាងប្រឡាក់ជាងពីមុនទៀត។ នៅពេលនេះ ពួកអ្នកដែលជាពូជរបស់ពស់(សត្វដូចមនុស្ស)បានបង្កើតគោលលទ្ធិផ្សេងៗ និងសិទ្ធាន្ត(ជឿមិនបាច់សួរ)នៅក្នុងជំនុំ ហើយកូនក្រមុំបានចូល***រួម ការសាហាយស្មន់ និង ការថ្វាយបង្គំរូបព្រះ។*** នាងបានក្លាយទៅជាថ្មជំពប់ដល់មនុស្សលោកីយ៍។ មានស្នាមប្រឡាក់ កន្លែងបន្ទោសបាន និងស្នាមជ្រីវជ្រួញជាច្រើន នៅលើ***សំលៀកបំពាក់*** របស់នាង។ ប៉ុន្តែ ព្រះអម្ចាស់នៅតែស្រឡាញ់កូនក្រមុំរបស់ទ្រង់ ហើយទ្រង់បានបញ្ជាក់ការនេះដោយចាត់ អ្នក*បរិសុទ្ធម៉ាទីន* ឲ្យមក ដែលជាម្នាក់នៃ***អ្នកកំដរកូនកំលោះទាំង៧*** នៅខាងស្ដាំព្រះហស្តរបស់ព្រះគ្រីស្ទ ដើម្បីឲ្យនាងប្រែចិត្ត។ នាងបានប្រែចិត្តប៉ុន្តែនៅ ***ថ្ងៃបន្ទាប់*** *(សម័យពួកជំនុំទី៤-វិវរណៈ ២:១៨-២៩)*នាងបានឲ្យគេឃើញកំហុសដោយអនុញ្ញាណឲ្យ*(ស្ត្រី យេស៊ីបិល)មកបញ្ឆោតអ្នកបំរើរបស់ព្រះអម្ចាស់នាង។* អារក្សដូចជាសិង្ហ ដែលកំពុងគ្រហឹម បានចាប់ផ្ដើមហែកញក់ញីនាង បានហែកសំលៀកបំពាក់នាងចេញ ដែលនាងបានថែរក្សាទុកជារបស់មានតម្លៃ។ **"ស្ត្រី យេស៊ីបិល" គ្មាននរណាទៀតទេក្រៅពី *"សេចក្ដីអាថ៌កំបាំង ក្រុងបាប៊ីឡូនដ៏ធំ ម្ដាយនៃស្រីសំផឹង និងជាសេចក្ដីគួរខ្ពើមនៃផែនដី" ហៅថា វិហាររ៉ូម៉ាំង (វិវរណៈ ១៧:៥)។ នាងជាស្ត្រីគ្រប់គ្រង (ជាទេវ៉ា)*** នៅសម័យនោះ។ នាងគឺជាភ្នាក់ងារបញ្ឆោតពិតរបស់អារក្ស បន្ទាប់ពីបានចាញ់បញ្ឆោតវាហើយ មានពេលឲ្យនាងប្រែចិត្តដែរ ប៉ុន្តែនាងមិនប្រែចិត្តទេ។ ហើយអស់រយៈពេល៩០០ ឆ្នាំ ដែលស្ត្រីដ៏អាក្រក់នេះបានប្លន់ និងបំផ្លាញការគ្រប់យ៉ាង ដែលជាពន្លឺ និងសេចក្ដីពិត ការល្អ និងសីលធម៌ សិល្បៈ វិទ្យាសាស្ត្រ និងអ្វីផ្សេងទៀតដែលមានប្រយោជន៍ដល់មនុស្សជាតិ។ ប៉ុន្តែដោយមានមនុស្សមានជំនឿ អ្នកបរិសុទ្ធកូឡាំបា ជា ***អ្នកនាំព្រះរាជសារ-ផ្កាយ***និង ជាមិត្តសម្លាញ់ ដែលព្រះគ្រីស្ទបានបញ្ជូនទៅឯកូនក្រមុំ ប្រេង (ព្រះវិញ្ញាណបរិសុទ្ធ) និងស្រាគ(ការរំភើបចង់បានការបើកសំដែង) បាននៅតែហូរដល់ពួកអ្នកជឿមួយចំនួន

តូច (ដែលបង្កើតជាកូនក្រមុំរើសតាំង)។ ពួកគេត្រូវបានប្រាប់ឲ្យកាន់ខ្ជាប់រហូតព្រះគ្រីស្ទយាងមកចុះ (វិវរណៈ ២:២៥)។ លើកលែងតែ ក្រុមតូចនោះទេ ដែលមិនបានកាន់ទាំងគោលលទ្ធិរបស់យេស៊ីបិល ឬដេកនៅគ្រែដដែលជាមួយនឹងនាងឡើយ ក្រៅពីនោះត្រូវព្រះជំនុំជំរះ។

ថ្ងៃទី៥ ***(សម័យពួកជំនុំទី៥-វិវរណៈ ៣:១-៦)*** គឺជាថ្ងៃងងឹតសំរាប់កូនក្រមុំ។ គឺនៅក្នុងសម័យនេះហើយ ដែលនាងស្ទើរតែត្រូវបានស្រាតសំលៀកបំពាក់ចេញពីនាង ដែលបានក្លាយទៅជារហែក និងដាច់រយ៉េរយ៉ៃ។ ហើយដោយរស់នៅក្នុងសេចក្តីងងឹតអស់រយះពេលជាយូរ នោះនាងអាចដើរក្នុងពន្លឺទាំងពិបាក។ ការគ្រប់យ៉ាងបានក្លាយទៅជា***អង្គការ។*** និងដូចជាស្ត្រីខ្វាក់ នាងបានដើរតាមប្រព័ន្ធទាំងមូលនៃឋានានុក្រមរបស់មនុស្ស របៀបពួកជំនុំគោលលទ្ធិផ្សេងៗ សិទ្ធាន្ត ការសូត្រមន្ត បុណ្យថ្វាយបង្គំរូបព្រះរបស់សាសន៍ដទៃ បុណ្យម៉ារី និងការរបស់អារក្សជាច្រើនប្រភេទទៀត ដែល ***"ស្ត្រី យេស៊ីបិលនោះ"*** បានបង្កើតឡើង។ បន្ទាប់មកកូនក្រមុំដ៏តូច (រួច មានតែពួកតិចតួចប៉ុណ្ណោះ ដែលមិនខូចខ្លួន) មិនបានបញ្ចប់ការងាររបស់នាងនៅចំពោះព្រះទេ។ នាងត្រូវបានហាមដោយព្រះរាជសារ ដែលកូនកំលោះ-ព្រះបន្ទូលរបស់នាង បានបញ្ជូនមកតាមរយៈ***អ្នកនាំព្រះរាជសារ*** របស់ទ្រង់ ***ម៉ាទីន លូទ័រ*** ឲ្យកាន់ខ្ជាប់នូវសេចក្តីពិត ដែលនាងបានទទួល និងយាមការពារព្រះបន្ទូលនោះ ហើយដើម្បីប្រែចិត្ត ដែលនាងអាចពាក់ដោយ ***"សំលៀកបំពាក់" (នៃសេចក្តីសុចរិត)។*** បាទនាងនឹងបានពាក់សំពត់ទេសយ៉ាងម៉ដ្ឋ ស្អាតហើយស ដូចជាគ្រាប់ខ្សាច់តិចតួចចុងក្រោយនៅក្នុងនាឡិកាដីខ្សាច់របស់ព្រះបានហូរស្រក់តក់ៗឆ្ពោះទៅកាន់ថ្ងៃទី៧-***ជាយុគសម័យនៃការបញ្ចប់សព្វគ្រប់។***

បាទ ថ្ងៃនោះបានចូលមកយ៉ាងលឿន។ ព្រះរាជបុត្រានៃព្រះមិនគ្រាន់តែស្រែក ***"មើលអញមកជាឆាប់"*** ប៉ុណ្ណោះទេ ទ្រង់ក៏បានបើកទ្វារចំហ ផងដែរ នៅថ្ងៃទី៦ ***(យុគសម័យពួកជំនុំទី៦-វិវរណៈ ៣:៧-១៣)។*** ទ្រង់នឹងយាងមកយកកូនក្រមុំទ្រង់ជាឆាប់ ដែលនាងមានកំលាំងតិច តែបានកាន់តាមព្រះបន្ទូល និងព្រះនាមរបស់ទ្រង់រហូតមកដល់ថ្ងៃនោះ។ នាងបានទទួលសេចក្តីសន្យាថា នាងនឹងមិនចូលទៅក្នុង ***"វេលានៃការល្បួងទេ ដែលត្រូវមកលើលោកីយ៍ទាំងមូល ដើម្បីនឹងល្បងដល់ពួកអ្នក ដែលនៅលើផែនដីទាំងប៉ុន្មាន"*** (វិវរណៈ ៣:១០)។ នាងបានដឹងថា វិវាហមង្គលរបស់ពួកគេនឹងត្រូវបញ្ចប់នៅថ្ងៃបន្ទាប់និង បន្ទាប់មកភ្លាមនោះ នាងនឹងត្រូវបង្ហាញថា ជាភរិយារបស់ទ្រង់ នៅឯ***ពិធីលៀងវិវាហមង្គលដ៏ធំនៃកូនចៀម*** (វិវរណៈ ១៩:៦-៨)។ បាទ ***សំលៀកបំពាក់*** របស់នាងបានកាន់តែស្អាតហើយ។ ប៉ុន្តែក្រៅពីកូនក្រមុំដ៏តូចនេះ តើមាននរណាទៀត ដែលនៅ ក្នុងសាសនា ក្នុងលោកីយ៍នេះ

ដែលបានប្រុងប្រយ័ត្ននឹងសម្រែកនោះ? តើមាននរណាទៀត ***បានគោរព*** បុគ្គលិកលក្ខណៈ នៃព្រះ ព្រះនាមទ្រង់ ព្រះបន្ទូលរបស់ទ្រង់ ឬក៏ កិច្ចការប្រោសលោះរបស់ទ្រង់?

***ពួកនិកាយ*** បានគិតថា ***"ទ្វារចំហ"*** មានតែនៅក្នុង***អង្គការ***របស់គេទេ ដែលអ្នកមានបាប អាចចូលមកក្នុងជំរកខាងវិញ្ញាណ។ ប៉ុន្តែ ***ទ្វារចំហ*** តែមួយគត់ គឺ (ហើយនៅតែចំហ) គឺ*ព្រះយេស៊ូគ្រីស្ទ* (យ៉ូហាន ១០:៧,៩)។ ទ្រង់បានសំដែងសេចក្ដីពិតដ៏វិសេសនេះតាមរយៈ***អ្នកបំរើរបស់ទ្រង់ គឺចនវ៉េសលី។*** ព្រះគ្រីស្ទ គឺជាការបើកសំដែងនៃព្រះ ដែលបំភ្លឺ***ផ្លូវ*** នៃ***ជីវិត*** ដល់កូនក្រមុំដ៏តូចនេះ និងដែលអាចឲ្យនាងកាន់តាមព្រះបន្ទូលរបស់ព្រះ និងដំកើងព្រះនាមទ្រង់។

អាម៉ែន ជាការពិត កំលាំងនឹងត្រឡប់មកដល់កូនពិតគ្រប់ ៗ រូបរបស់ព្រះយ៉ាងលឿន។ព្រះនឹងធ្វើការយ៉ាងរហ័ស។ ទ្រង់នឹងបន្ថយថ្ងៃនើឲ្យខ្លី ដែលនៅខាងមុខ។ ទ្រង់បានទតឃើញសេចក្ដីជំនឿនៃអ្នករើសតាំងម្នាក់ៗ ដ្បិតទ្រង់បានសាកគេរាល់គ្នា ដែលហ៊ានទទួលសេចក្ដីសន្យារបស់ទ្រង់ រហូតដល់ ព្រះបន្ទូលសន្យាបានមកដល់(ទំនុកតំកើន ១០៥:៩)។ ពួកបរិសុទ្ធបានរៀនពីការអត់ធ្មត់នៃព្រះគ្រីស្ទ និងបានទទួលកំលាំងនៃជិវិត។ ***សំលៀកបំពាក់រៀបការ*** (នៃសេចក្ដីសង្គ្រោះ) របស់កូនក្រមុំ បានត្រឡប់ទៅជារាងល្អជាមុន នៅពេលនាងទាញខ្លួននាងចេញពីប្រព័ន្ធរបស់មនុស្ស និង រៀបខ្លួនជាស្រេចនៅក្នុងការបើកសំដែងនៃព្រះបន្ទូលសំរាប់ការយាងមកនៃ កូនកំលោះ-ព្រះបន្ទូល។

**បទចំរៀងនៃសាឡូម៉ូន ជំពូក៥**
ខ្ញុំបានដេកលក់ហើយ តែចិត្តខ្ញុំនៅភ្ញាក់ទេ នោះឮសំឡេង
របស់ស្ងួនសម្លាញ់ខ្ញុំ ទ្រង់គោះទ្វាថា *ឱប្អូន ជាមាសសម្លាញ់ ឱ*
*ព្រាបរបស់អញ ជាអ្នកបរិសុទ្ធរបស់អញអើយ ចូរបើកទ្វារឲ្យអញ។*

ពួកបរិសុទ្ធអើយ យើងកំពុងរស់នៅចុងថ្ងៃទាំង៧ហើយ (យុគសម័យពួកជំនុំទី៧)គឺថានឹងជាថ្ងៃដែលខ្លីបំផុត ព្រោះព្រះបានបន្ថយថ្ងៃនោះឲ្យខ្លី ដោយការ*យ៉ាងរហ័ស១*។ នោះគឺជ ***"វាលាពេលល្ងាច"*** ហើយកូនកំលោះនៅស្ថានសួគ៌ ជាព្រះបន្ទូលនៃព្រះ បានមកដើម្បីប្រកាសពីកូនក្រមុំ-ព្រះបន្ទូលរបស់ទ្រង់(១ថែស្សាឡូនិច៤:១៦,វិវរណៈ១០:១-៧)។ ***វត្តមាន*** របស់ទ្រង់ (ពាក្យក្រិក:***ប៉ារ៉ូស៊ៀ***)បានប្រាប់ឲ្យដឹងជាមុនដោយ***វិល្លាម ប្រាណហាំ*** ដែលមិនគ្រាន់តែជា ***អ្នកនាំព្រះរាជសារចុងក្រោយ*** និង***ទី៧*** របស់ទ្រង់ ប៉ុន្តែក៏ជាអ្នកបំរើ និង មិត្តសម្លាញ់របស់ទ្រង់ដែរ។ គាត់ត្រូវបានចាត់មក ដើម្បីរៀបកូនក្រមុំជាស្រេចសំរាប់រៀបការ។ ***ការយាងមកដល់នៃ***

*កូនកំលោះ ត្រូវបានប្រកាសដល់កូនក្រមុំ នៅពេលដែលអ្នកនាំព្រះរាជសារនោះ ស្រែកឡើង "នែ ប្តីមក ហើយ! ចូរចេញទៅជួបទ្រង់ចុះ"* (ម៉ាថាយ ២៥:៦,បទចំរៀងសាឡូម៉ូន ៥:២)។ *សម្រែក* ជា អ្នកបើកទ្វារ ដើម្បីឲ្យអ្នកកាន់សាសនាបានរៀបចំចេញពីព្រះគ្រីស្ទ *ព្រះបន្ទូល* ដោយខ្ទាក់ នៅពេលដែលទ្រង់យាងមករៀបការជាមួយកូនក្រមុំរបស់ទ្រង់(វិវរណៈ ៣:២០)។ នៅពេលដែលវិហារសាសនាពីភពលោកបានបដិសេធទ្វារចំហរបស់ព្រះគ្រីស្ទ ពួកគេបានធ្វើទ្វាររបស់ខ្លួន ដើម្បីនាំមនុស្សចូល ចំពេលដែលពួកគេចូលទៅក្នុង *កតិកានៃការប្រូបរួមពិភពលោកតែ១* ដើម្បីបង្កើតរូបភាពដល់សត្វសាហាវរ៉ូម៉ាំង(វិវរណៈ ១៣,១៨:៤)។ ពួកគេទៅជាស្ទើរៗ(ក្តៅឧណ្ហៗ)មិនច្រូតព្រលឹកមនុស្ស តែបែរជាច្រូតភាពមាននៅលើលោកីយ៍នេះវិញ។ ពួកគេមិនដឹងថា ពួកគេវេទនា លំបាក(ទុគ៌ត)ទាល់ក្រ ខាក់ភ្នែក ហើយអាក្រាតនៅចំពោះព្រះនេត្រព្រះនោះទេ។ មានតែកូនក្រមុំទេ-ដែលនឹងឮសំលេងនៃមហាទេវតាមាស សំឡាញ់របស់នាង។ នាងនឹងចេញពីស្ថានភាពនោះ ហើយចូលទៅក្នុងពិធីជប់លៀងនៃ**អាពាហ៍ពិពាហ៍** ហើយនឹងបានប្រកបជាមួយទ្រង់ដែលជាព្រះបន្ទូលនៃព្រះ។ នាងកំពុងតែទិញមាស ដែលបានប្រទានមកនាង។

## ការប្រកបដ៏មើលមិនឃើញ

ពួកស្ងួនភ្ងាអើយ នេះជាពេលវេលាប្រកបរួមគ្នា។ វាជាការប្រកបដ៏មើលមិនឃើញនៃកូនក្រមុំ និងកូនកំលោះ។ ព្រះអម្ចាស់គង់នៅទីនេះ! ស្តេចនៅទីនេះ! ព្រះបន្ទូលនៅទីនេះ! ចូរអ្នកចូលទៅក្នុងត្រសាល នៃសេចក្តីស្រឡាញ់ចុះ! ចូរនៅស្និទ្ធស្នាលនឹងទ្រង់ចុះ! ចូរចូលទៅក្នុងភាពជាប្តីប្រពន្ធជាមួយទ្រង់ ហើយបំពេញការសច្ចារៀបអាពាហ៍ពិពាហ៍ចុះ! អ្នកនឹងបានទៅជាភរិយារបស់ទ្រង់ *ឥឡូវនេះ* ដែរ ឬក៏មិនបានធ្វើដែរ។

## ក្បួនដង្ហែរវិវាហមង្គល

នៅក្នុង *ក្បួនដង្ហែរ* វិវាហមង្គល ផ្នែកខាងអាស៊ី កូនកំលោះបានស្លៀកពាក់សំលៀកបំពាក់ល្អស្អាតដាច់គេ និងលាបគ្រឿងក្រអូប ដោយមានប្រដាប់ពាក់លើក្បាលយ៉ាងសង្ហារដែលធ្វើពីកម្រងផ្កា ឬស្លឹកឈើ នៅលើក្បាលរបស់គាត់ ដូចជាស្តេច (បទចំរៀង នៃសាឡូម៉ូន ៣:១១,អាសាយ ៦១:១០,វិវរណៈ ១០:១) គាត់នឹងចាប់ផ្តើមចេញដំណើរពីផ្ទះរបស់គាត់នៅឯផ្ទះកូនក្រមុំ។ (ពួក) មិនសម្លាញ់នៃកូនកំលោះ ដែលមានអ្នកភ្លេង និង អ្នកច្រៀងទៅជាមួយនឹងទៅមុនកូនកំលោះ (លោកុប្បត្តិ ៣១:២៧,ទំនុកដំកើង ៤៥:១៥,យេរេមា ៧:៣៤)។ ជាធម្មតា ដំណើរការនឹងទៅដល់ផ្ទះដូចក្រមុំយឺត *នៅពេលល្ងាច* ដែលជាហេតុធ្វើឲ្យគេត្រូវការ

ចង្កៀង(ម៉ាថាយ ២៥:១)។ មានមូលហេតុ២សំរាប់ការនេះ : ១គឺមានចំងាយឆ្ងាយណាស់ រវាង ផ្ទះទាំង២នៃគូស្វាមីភរិយា ហើយ១ទៀតគឺមានកំដៅក្តៅនៅពេលរសៀល។ (ចំណាំ: មានការសន្មត់ថា ភាគីទាំង២បានផ្តើមចេញពីផ្ទះ ដែលគួរឲ្យគោរពរៀងៗខ្លួន ដើម្បីទៅជួបគ្នានៅពាក់កណ្តាលផ្លូវ។ ការនេះប្រហែលជាគ្មានគេធ្វើទេ ឬលែងមានហើយ។)

នៅពេលដែលកូនកំលោះមកដល់ផ្ទះកូនក្រមុំ កូនក្រមុំ បានស្លៀកពាក់សំលៀកបំពាក់រៀបការរបស់នាងរួចជាស្រេច (ទំនុកដំកើង ២៥:១៣-១៤,យេរេមា ២:៣២) ហើយយកស្បៃយ៉ាងក្រាស់មកបាំងមុខ (លោកុប្បត្តិ ២៤:៦៥,២៩:២១-២៥)។ បន្ទាប់ពីទទួលកូនក្រមុំហើយ ទាំងអស់គ្នាទទួលការឲ្យពរពិឪពុកម្តាយរបស់នាង ក៏ដូចជាទទួលពរល្អៗពីសាច់ញាតិ និងពួកមិត្តសម្លាញ់ (លោកុប្បត្តិ ២៤:៥៩-៦០,នាងរស់ ៤:១០-១២) នៅក្នុងចំណោមភាពសប្បាយរីករាយ នៃការច្រៀង រាំ ស្រែក និងត្រេកអរ កូនកំលោះ និងភាគីទាំងអស់របស់គាត់នឹងធ្វើដំណើរទៅផ្ទះរបស់គាត់វិញ ឬផ្ទះរបស់ឪពុកគាត់ សំរាប់***បរិភោគការ។***ទោះជាយ៉ាងណាក៏ដោយ បើកូនកំលោះរស់នៅទីឆ្ងាយ ការបរិភោគជាធម្មតាដែលធ្វើនៅពេលយប់នឹងរៀបចំដំបូងនៅផ្ទះឪពុកម្តាយរបស់កូនក្រមុំ ដោយការចំណាយណាមួយក៏បាន កូនកំលោះ ឬឪពុកម្តាយរបស់កូនក្រមុំ(លោកុប្បត្តិ ២៩:២២,ពួកចៅហ្វាយ ១៤:១២)។ ជាធម្មតា គេលើកស្រាមកជូនជាគ្រឿងលើកទឹកចិត្ត នៅកំឡុងពេលបរិភោគ(មើល យ៉ូហាន ២:៣)។ ***(ចូរចាំថា ការបរិភោគនេះអាចមានតទៅច្រើនថ្ងៃទៀត***-លោកុប្បត្តិ ២៩:២៧,ពួកចៅហ្វាយ ១៤:១២)។ នេះគឺជាទីបន្ទាល់១ ដល់មនុស្ស ដែលរស់នៅក្នុងបរិវេណ ដែលស្រីក្រមុំនោះបានរៀបការជាមួយនឹងមាសសម្លាញរបស់នាងហើយ ឥឡូវនេះ។ (បើសិនជាគូស្វាមីភរិយាបានរស់នៅក្នុងភូមិដូចគ្នា ការបរិភោគនឹងប្រព្រឹត្តឡើងនៅ ផ្ទះកូនកំលោះឬ ផ្ទះឪពុករបស់គាត់។)

## បន្ទប់ពិសេស

ដំបូង កូនកំលោះ និងកូនក្រមុំដែលត្រូវនាំមកទាំងអស់គ្នា(យ៉ូហាន៣:២៩០) នឹងធ្វើសច្ចារៀបអាពាហ៍ពិពាហ៍ជាថ្មី ដែលពួកគេធ្វើ នៅពេលធ្វើពិធី ភ្ជាប់ពាក្យរបស់ពួកគេ នៅចំពោះការជួបជុំនៃមនុស្ស។ ចំពោះពួកយូដា សព្វថ្ងៃនេះ ត្រូវធ្វើឡើងក្រោមប៉ារាំ ហៅថា ***ជុបប៉ា***(chuppah)ក្នុងភាសាហេព្រើរ។ **វាតំណាងឲ្យការប្រារព្ធពិតនៃការនាំកូនក្រមុំនៅផ្ទះជាការពិត** ***ជុបប៉ា*** វិវត្តមកពីត្រសាល(តង់)ដែលនៅសម័យបុរាណ **ត្រូវបានប្រើផងដែរជាបន្ទប់ពិសេស។** (មើលលោកុប្បត្តិ ២៤:៦៧,ម៉ាឡាគី ២:១៤,អេសេគាល ១៦:១៨,ម៉ាថាយ ២៣:៣៧-៣៨)។

នៅពេលការបរិភោគ និង ភាពសប្បាយរីករាយ បានបន្ត កូនក្រមុំ និងកូនកំលោះនឹងត្រូវតែហែរហមជូនទៅបន្ទប់ពិសេស នៅមុនចប់ពេលល្ងាច គឺទាំងឪពុកម្តាយរបស់ពួកគេនិងពួកមិត្តសម្លាញ់(លោកុប្បត្តិ២៩:២៣,ចៅហ្វាយ១៥:១) វាគឺជា ត្រសាលនៃសេចក្តីស្រឡាញ់ ដែលគូស្វាមីភរិយានឹងបញ្ចប់វិវាហមង្គលរបស់ពួកគេ។ ពួកគេនឹងស្គាល់គ្នាយ៉ាងស្និទ្ធស្នាល ដូចជាប្តី និងប្រពន្ធ(ម៉ាថាយ ២៥:១២)។សន្ធះព្រហ្មចារីរបស់ស្ត្រីនោះ នឹងត្រូវបើកឡើងនៅទីនេះ ហើយភស្តុតាង(សញ្ញា) បានទទួល (ចោទិយកថា ២២:១៣-២១)។

មែនហើយ ដូចដែលកូណកំលោះបានព្រួយបារម្ភយ៉ាងខ្លាំង ថានេះគឺជាផ្នែកសំខាន់បំផុតនៃ***ការប្រារព្ធពិធីវិវាហមង្គល។*** គឺ នៅត្រង់នេះហើយ ដែលគាត់នឹងស្គាល់***អត្តសញ្ញាណពិតនៃកូនក្រមុំ។*** នេះប្រហែលជា ចំឡែក ដល់មនុស្សភាគច្រើន។ ប៉ុន្តែចូរសំគាល់ពីរបៀបដែលយ៉ាកុបចាញ់បញ្ឆោតឡាបាន់ ជាឪពុកក្មេករបស់គាត់ ដែលបានប្តូរ៉ាជែល ជំនួសដោយលេអានៅថ្ងៃរៀបអាពាហ៍ពិពាហ៍ (មើលលោកុប្បត្តិ ២៩:២១-២៥)។ មែនហើយ តើដូចម្តេចបានជារឿងនេះអាចទៅជាយ៉ាងហ្នឹង? ទោះជា មិនបានអនុវត្តនៅ សម័យទំនើបនេះកូនក្រមុំផ្នែកខាងអាស៊ីពីបុរាណ ត្រូវពាក់ស្បៃមុខយ៉ាងក្រាស់នៅថ្ងៃរៀបអាពាហ៍ពិពាហ៍។ ស្បៃបាំមុខនេះមិនត្រូវដកចេញពីមុខរបស់នាងឡើយពេញ១ថ្ងៃនិងពេលល្ងាច។ គឺមានតែប្តីរបស់នាងប៉ុណ្ណោះទើបអាចបើកវាបាននៅក្នុង ***ជុបប៉ា*** បន្ទប់ពីបរិភោគរួច។ នៅខណៈបើកស្បៃចេញពីកូនក្រមុំ យ៉ាកុបត្រូវបានគេបញ្ចុះបញ្ចូលមិនអោយ***បើកភ្លើង*** ហើយពេលស្អែក បានមកដល់ គាត់មានសេចក្តីស្រងាកចិត្ត ដោយគាត់ត្រូវគេបោកបញ្ឆោត។

## វិវាហមង្គលនៃកូនចៀម

មែនហើយ អ៊ីសាករបស់យើង ក្នុងរូបរាងជា ***ព្រះបន្ទូល*** បានយាងមកពីផ្ទះរបស់ទ្រង់តាមផ្លូវដ៏វែងដើម្បីទទួលកូនក្រមុំរបស់ទ្រង់។ ទ្រង់ ព្រះពស្ត្រ ដោយសំលៀកបំពាក់ល្អស្អាតដាច់គេ និងលាបគ្រឿងក្រអូប(សំលៀកបំពាក់ពេញដោយព្រះបន្ទូល និងការបើកសំដែង)ដែលមានប្រដាប់ពាក់នៅលំព្រះសិរទ្រង់(វិវរណៈ ១០:១)។ ទ្រង់ជាស្តេច!ហើយទ្រង់យាងមកយកមហេសីរបស់ទ្រង់!ហាលេលូយ៉ា!

ធ្លាប់មានការផុសផុលដ៏អស្ចារ្យ១ នៅដើមសតវត្សទី២០ នៅពេលដែលអ្នកនាំព្រះរាជសារយុគសម័យពួកជំនុំទី៧បានមកដោយសំរែក១ ដើម្បីបន្លឺពីណើរនៃកូនកំលោះជាព្រះបន្ទូល(១ថែស្សាឡូនិច ៤:១៦,សាការី ៤:៧)។ គឺបានបន្លឺឡើងនៅវេលាពេលល្ងាចអ្នកនាំព្រះរាជសារនោះបានមកដោយព្រះរាជសារ១ (ពន្លឺ) នៃព្រះ ដោយស្រែកចេញទៅថា ***"នែ ប្តីមកហើយ! ចូរចេញទៅជួបទ្រង់ចុះ! ចូរចេញពី***

វិវាហមង្គលនៃកូនចៀម

*បាប៊ីឡូនមក ហើយចូលទៅក្នុងបរិភោគជាមួយកូនកំលោះ!”* (ម៉ាថាយ ២៥:៦, វិវរណៈ ១៨:៤,៣:២០)។ ព្រះគ្រីស្ទបានយាងមកដើម្បីកាសពីកូនក្រមុំព្រះបន្ទូលទ្រង់! វាគឺជាពេលនៃភាពសប្បាយរីករាយស្រែក ច្រៀង រាំ និងត្រេកអរនៅក្នុងផ្នែកខាងវិញ្ញាណ។ *ដំណើរការផុលផុស* នេះមានមនុស្ស១ចំនួនធំនៅលើពិភពលោកបានធ្វើបន្ទាល់ពីការនេះ។

[ចំណាំៈនៅក្នុងគំរូ ឬប្រភេទវិទ្យា គឺការសិក្សាអំពីគំរូ ឬប្រភេទ យើងមិនគួរយកអត្ថបទ ឬខគម្ពីរ យ៉ាងសាមញ្ញ និងនិយាយច្រំដែលៗច្រើនពេកនោះទេ។ បើពុំដូច្នោះទេ យើងនឹងដឹងខ្លួនយើងថា កំពុងតែទាញមមុង និងកំពុងលាបអូដ្ឋ។ ឥឡូវនេធ ផ្អឹកលើលោកុប្បត្តិ ២៤:៦៣ អ្នកខ្លះជឿហួសហេតុថា វិវាហមង្គលរបស់កូនក្រមុំ-ព្រះបន្ទូល និងកូនកំលោះព្រះបន្ទូល មិនកើតឡើងនៅផែនដីទេ ប៉ុន្តែនៅស្ថានសួគ៌វិញ។ ពួកគេពោលអះអាងថា ដូចជាអ៊ីសាកបានជួបរេបិកានៅកណ្ដាលផ្លូវ នោះព្រះគ្រីស្ទយេស៊ូក៏នឹងជួបកូនក្រមុំរបស់ទ្រង់នៅកណ្ដាលផ្លូវរវាងស្ថានសួគ៌ និងផែនដីដែរដើម្បី យកនាងទៅដំណាក់ព្រះវរបិតាទ្រង់ហើយ រៀបការជាមួយនាងនៅទីនោះ។ ប៉ុន្តែសូមឲ្យខ្ញុំរំលឹកពួកគេថា *វិវាហមង្គលនៃកូនចៀមនៃព្រះ* គឺជាពិធីខាងវិញ្ញាណទេ និង មិនមែនពិធីរៀបការរបស់មនុស្សរវាង បុរសនិងស្ត្រីដែរ។ ខ្ញុំចង់ឲ្យយោបល់ពួកគេថា ឲ្យអានពាក្យនៅក្នុងលោកុប្បត្តិ ២៤:៦៣នៅក្នុងអត្ថបទដ៏ត្រឹមត្រូវ ម្ដងទៀតទៅ។ អ៊ីសាក មិនបានចេញទៅទីវាលដើម្បីជួបរេបិកាទេ។ គាត់បានចេញទៅទីនោះ ដើម្បីសញ្ជឹងគិត នៅណេៈដើរលំហែរ។ គាត់មិនបានគិតថា អាលាសើរបានរកឃើញកូនក្រមុំសសំរាប់គាត់ ហើយ ថាគាត់បានត្រឡប់មកនៅពេលជាក់លាក់នោះទេ។ ការពិត តួអង្គសំខាន់នៅក្នុងរឿងនោះ គឺអេលាសើរ។ អ័ប្រាហាំ បានចាត់គាត់ឲ្យទៅឯណាឃរ ក្នុងក្រុងមេសូប៉ូតាមាដើម្បីនាំកូនក្រមុំសំរាប់កូនរបស់គាត់ គឺអ៊ីសាក។ ហើយក្រោយពីអេលាសើរឃើញរេបិកា គាត់ក៏នាំនាងទៅអ៊ីសាក ដែលត្រូវរៀបការជាមួយនាង។]

ពួកស្ងួនភ្ងាអើយ សូមកុំឲ្យយើងធ្វើដូចជាពួកគ្រីស្ទមានតែឈ្មោះ ដែលគិតតែនិងស្វែងរក ការលេចមកមែនទែន *(ពាក្យក្រិកៈ អេពីផានៀ)* នៃព្រះអម្ចាស់យេស៊ូគ្រីស្ទមកយកកូនក្រមុំទ្រង់។ បទគម្ពីរបរិសុទ្ធបានបង្ហាញថា ដូច*ការយាងមករបស់ព្រះគ្រីស្ទលើកទី១* ដើម្បីសំដែងអង្គទ្រង់ជាព្រះមែស៊ីដល់រាស្ត្ររបស់ទ្រង់ ពួកកូនចៅអ៊ីស្រាអែលឯ*ការយាងមកលើកទី២របស់ទ្រង់ក្នុងកំឡុងពេលវេលា១* ដូច្នេះ ការបើកសំដែង(ពាក្យក្រិកៈ*អាប៉ូកាឡីបស៊ីស*)របស់ទ្រង់មានជាដំណាក់កាល់ៗ។

ការយាងមកលើកទី១ នៃព្រះអម្ចាស់យេស៊ូគ្រីស្ទ មានកំឡុងពេលប្រហែល ៣០ឆ្នាំ។ វត្តមាន (ពាក្យក្រិកៈ *ប៉ារ៉ូសៀ*) នៃព្រះគ្រីស្ទ *(ព្រះបន្ទូលដ៏មានប្រេងតាំង)* បានបង្ហាញនៅលើឆាក *នៅពេលដែល* ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់នាងព្រហ្មចារីម៉ារី ដើម្បី*ប្រកាសពីការចាប់មានគភ៌ដ៏អស្ចារ្យមិនធម្មតា។* បន្ទាប់មកហោរាយ៉ូហាន-បាទីស្ទបានមកដើម្បី រៀបចំផ្លូវដោយប្រកាស **ព្រះរាជសារឲ្យដឹងជាមុន**ពីការលេចមកជាឆាប់របស់ទ្រង់ហើយទីបំផុត នៅពេល*សេចក្តីពោរពេញនៃព្រះបានយាងមក សណ្ឋិតក្នុងរូបកាយ ព្រះយេស៊ូនៅពេលធ្វើពិធីបុណ្យជ្រមុជទឹកឲ្យទ្រង់* នោះក៏មានការលេចមកមែនទែន (ពាក្យក្រិកៈEisodos*អេសូដុស*-ការយាងចូលមកខាងក្នុង,កិច្ចការ១៣:២៤) នៃព្រះគង់ក្នុងសាច់ឈាម។

ដូចគ្នាដែរ ការយាងមកវិញរបស់ទ្រង់លើកទី២បានចាប់ផ្តើម នៅពេលអ្នកនាំព្រះរាជសារ-ផ្កាយទី៧ និងចុងក្រោយរបស់ទ្រង់បានមកដោយ(សំរែក)ព្រះរាជសារ ១ *"នែ ប្តីមកហើយ!ចូរចេញទៅទទួលទ្រង់ចុះ!"* វត្តមាននៃព្រះគ្រីស្ទ ព្រះបន្ទូលដ៏មានប្រេងតាំងបានយាងមកដោយសេចក្តីប្រកាស។ វត្តមានរបស់ ទ្រង់គឺនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ ដូចជាពួកកូនចៅអ៊ីស្រាអែលនៅទីរហោស្ថាន គឺពួកបរិសុទ្ធនៅសតវត្សទី២០នេះដែលមិនគ្រាន់តែឃើញបង្គោលភ្លើង និងផ្សែង(ពពក)ដ៏មានសិរីល្អដែលបញ្ជាក់ពីប៉ារ៉ូសៀ នៃព្រះអម្ចាស់នៅចំណោមរាស្ត្ររបស់ទ្រង់ ប៉ុន្តែក៏បានឃើញ *ទីសំគាល់នៃវត្តមានរបស់ទ្រង់ផ្ទាល់* ផងដែរនៅក្នុងព័ន្ធកិច្ចនៃហោរាវីល្លាម ប្រាណហាំ(ម៉ាថាយ២៤:៣,២៧-២៨,៣៧-៣៩)។ *ប៉ារ៉ូសៀ* នៃព្រះអម្ចាស់យេស៊ូគ្រីស្ទនៅក្នុងព្រះបន្ទូលនាំមកនូវ *អាប៉ូកាឡឹបស៊ីស (ការបើកសំដែង* នោះគឺជាការបើកស្បៃ បើកប្រដាប់គ្របបាំង ការបង្ហាញឲ្យឃើញ ឬការនាំទៅឯពន្លឺ)នៃព្រះនៅក្នុងព្រះគ្រីស្ទ និងនៃសេចក្តីពិតរបស់ទ្រង់ ដែលលាក់ទុកនៅក្នុងបទគម្ពីរជាពិសេស គម្ពីរវិវរណៈ។ បន្ទាប់មក នេះបើកឲ្យឃើញ ឬសំដែងចេញ (ពាក្យក្រិកៈ *ផានេរូPhaneroo*) ពីអត្តចារិកពិតរបស់នរណាម្នាក់ និង ឈរនៅក្នុងព្រះអម្ចាស់។ ហើយពួកអ្នកដែលសក្តិសមនឹងព្រះនាមទ្រង់នឹងត្រូវដកឡើង (ឬឆក់ឡើង លើកឡើង) ដើម្បីជួបព្រះអម្ចាស់យេស៊ូគ្រីស្ទ នៅក្នុង *អេពីផានៀ* (ការសេចមកដ៏មានសិរីល្អមែនទែនក្នុងទំរង់ជារូបកាយ)របស់ទ្រង់ នៅនាអាកាស។

(ដោយសារតែខ្វះការយល់ដឹងទៅទៅនៃអាស៊ីនិយមនៃគម្ពីរ ហើយ ទំនៀមទំលាប់ និងប្រពៃណីរបស់ពួកខាងកើត មានមនុស្សជាច្រើនបានដឹងថា វាជាការលំបាកឲ្យយល់វិវាហមង្គលនៃកូនចៀម។ ប៉ន្តែ ខ្ញុំបានអធិស្ឋាន សូមឲ្យព្រះប្រទានប្រាជ្ញាខាងវិញ្ញាណដល់អ្នកដើម្បីយល់គំរូទាំងនេះនៅក្នុងការសិក្សានេះ ដោយរក្សា

ទុកក្នុងគំនិតថា ការខាងធម្មជាតិជាគំរូពីការខាងវិញ្ញាណ។) ពិតមែនហើយ***វិវាហមង្គល!*** ឥឡូវកូនក្រមុំបានរៀបខ្លួនជាស្រេច សំរាប់ វិវាហមង្គលដែលនាងបាន កំពុងរង់ចា អស់រយៈពេលជាយូរមកហើយ។ ឥឡូវនេះ នាងកំពុងតែប្រដាប់ដោយ សំលៀកបំពាក់រៀបការ នៃសេចក្តី សង្គ្រោះរបស់នាង និងបានបាំងស្បៃមុខជិតហើយ ដ្បិតនាងជារបស់មនុស្សពិសេសម្នាក់គត់ ដែលនឹង បើកឲ្យឃើញ និងបើកស្បៃមុខនាងនៅក្នុងជុបប៉ា។ នេះជាពេលរួមគ្នា! ការប្រកបដ៏មើលមិនឃើញរវាងកូនក្រមុំ និងកូនកំលោះកំពុងតែកើតឡើងឥឡូវនោះហើយ! សូមថ្វាយព្រះពរព្រះនាមព្រះអម្ចាស់!។

> នេះម៉ោងនាពេលល្ងាច!
> នេះជាពេលរៀបវិវាហមង្គល!
> នេះជាពេលរួមគ្នា!
> នេះជាការប្រកបដ៏មើលមិនឃើញ
> រវាងព្រះគ្រីស្ទ និងកូនក្រមុំរបស់ទ្រង់!
> ព្រះគ្រីស្ទកំពុងនាំកូនក្រមុំរបស់ទ្រង់
> នៅដំណាក់ព្រះវរបិតាទ្រង់!

## ការរៀបនំម៉ាណានៅលើតុ

ការដំបូងដែលកូនកំលោះព្រះបន្ទូលធ្វើ ចំពោះការអះអាងកូនក្រមុំរបស់ទ្រង់ គឺត្រូវរៀបចំ ការបរិភោគការ(ពិធីលៀងវិវាហមង្គល) សំរាប់ពួកបរិសុទ្ធនៃព្រះ។ ស្រា លើកទឹកចិត្តនៃព្រះវិញ្ញាណនៃការបើកសំដែងប្រទានឲ្យពួកគេមាន កំលាំង និង អំណរ។ ព្រះពន្ទូលនៃព្រះ កូនកំលោះ គឺជាពន្លឺ។ ទ្រង់គឺជាផ្កាយថ្ងៃ(ព្រះអាទិត្យ) ដែលពន្លឺរបស់ទ្រង់កំពុងបន្ទុំជីវិតនៃពួកបរិសុទ្ធ។ នៅខាងក្រៅការបរិភោគការ នេះមានសេចក្តីងងឹតនិង សេចក្តីស្លាប់ខាងឯវិញ្ញាណ(ម៉ាថាយ២២:១៣,២៥:៦)។ ដរាបណា ពិធីរៀបការបន្តនៅផ្ទះ (ផែនដី) នៃកូនក្រមុំ នោះ ការបរិភោគ នឹងបន្តទៀតដែរ។ ហើយពួកអ្នកដែលគ្មាន សំលៀកបំពាក់រៀបការ ក៏ត្រឹមត្រូវ ដែលប្រទានដោយព្រះអម្ចាស់ នឹងមិនអនុញ្ញាតឲ្យ ចូលមកខាងក្នុងដើម្បីចូលរួម ការបរិភោគ នេះឡើយ (ម៉ាថាយ ២២:១១-១២)។ សំលៀកបំពាក់ផ្ទាល់ ខ្លួនរបស់ពួកគេនឹងមិនអាចទទួលយកបានឡើយ (អេសាយ ៤:១)។

## ជុបប៉ា

ទោះបីយ៉ាងណាក៏ដោយ វាជារឿង១សំរាប់ពួកបរិសុទ្ធ ដើម្បីបរិភោគ ជាមួយព្រះអម្ចាស់ ប៉ុន្តែរឿង១ទៀតសំរាប់ពួកគេ ដើម្បីមានអត្តញ្ញាណ ជា**អវៈយវៈ**នៃកូនក្រមុំពិតដូចជាកូនក្រមុំផ្នែកខាងអាស៊ី **អត្តញ្ញាណ**នៃកូនក្រមុំពិតរបស់ព្រះគ្រីស្ទ គឺមានតែសំដែងនៅក្នុង***ជុបប៉ា*** ប៉ុណ្ណោះ ដែលជា***ព្រះបន្ទូលនៃព្រះ***។ មែនហើយ ***ព្រះបន្ទូលនៃព្រះ*** គឺជា*ប្រដាប់គ្របបាំង កន្លែងគាំពារ និងការការពារ*របស់យើង។ គឺជាផ្ទះរបស់យើង ជាវិហារ(រោងឧបោសថ)របស់យើង នៅទីរហោស្ថាននៃពិភពលោក

(ម៉ាថាយ ២៣:៣៧, ភីលីព ១:៣-២១, អេភេសូរ ៦:១៧) (សូមចាំថា *ដុបប៉ា* តំណាងឲ្យ***ផ្ទះដែលនាំមក***នៃកូនក្រមុំ)

ពួកគ្រីស្ទានមានតែឈ្មោះ រាប់មិនអស់បានអះអាងថា ជាសាមាជិកនៃកូនក្រមុំពិតរបស់ព្រះគ្រីស្ទ។ ពួកគេអាចអះអាងថា ពួកគេបានរៀបការជាមួយព្រះគ្រីស្ទ និងកំពុងបរិភោគជាមួយនឹងទ្រង់។ ទោះជាយ៉ាងណាក៏ដោយ **តេស្ត**ចុងក្រោយ និងផ្តាច់ព្រាត់ គឺថាតើ ព្រះយេស៊ូគ្រីស្ទស្គាល់ពួកគេឬទេ។ ហើយគឺនៅក្នុង*ដុបប៉ា* នៃព្រះ បន្ទូលនៃព្រះ ដែលអ្នកថ្វាយបង្គំពិត នៃព្រះពិតតែ១ នឹងត្រូវមានកន្លែងសំគាល់។ គ្រប់គ្នានឹងឮការប្រកាសចេញមក ទាំង ***"អញស្គាល់ឯង"*** ឬ ***"អញមិនស្គាល់ឯងទេ"*** (មើលម៉ាថាយ ៧:២៣, ២៥:១២)។ ***"ដ្បិតហៅមកច្រើន តែរើសបានតិច"*** (ម៉ាថាយ ២២:១៤)។ ជាការពិត ឥឡូវនេះទ្រង់ កំពុងតែគង់នៅដើម្បីនឹងញែកពួកអ្នករើសតាំង ដែលនឹងធ្វើជាកូនក្រមុំរបស់ទ្រង់ពីអ្នកដទៃទៀត។

## ការបើកស្បៃ បើកប្រដាប់គ្របបាំង

នៅក្នុង***ដុបប៉ា*** កូនកំលោះ-ព្រះបន្ទូល នឹងបើកស្បៃកូនក្រមុំរបស់ទ្រង់ ដើម្បីមើល**អត្តសញ្ញាណ**ពិតរបស់នាង។ យ៉ាកុបមិនអាចមានញាណល្មមនឹង***បើកភ្លើង*** ដើម្បីមើលថាតើកូនក្រមុំរបស់គាត់គឺ រ៉ាជែល ឬ ក៏អត់ ប៉ុន្តែអ៊ីសាក ពិតជានឹង***បើកភ្លើង ដុបប៉ា*** ចំពេលដែលគាត់***បើកស្បៃ*** កូនក្រមុំរបស់គាត់។ គាត់នឹងដឹងយ៉ាងជាក់ថា នាងគឺជារេបិកា និងមិនមែន**ស្ត្រីផ្សេងទៀតទេ (វិហារឯករាជ្យ)** ឬវិហាររបស់ពួកស្ត្រីសំផឹង (វិហារនិកាយ) ដែលកំពុងក្លែងខ្លួនធ្វើជាកូនក្រមុំរបស់ទ្រង់ (វិវរណៈ ១៧:១-៦)។ ឥឡូវ នេះគ្រាន់តែជាជំហានទី១ក្នុងការចាប់ផ្តើម**ស្គាល់**នាង បន្ទាប់មកទៀត ទ្រង់នឹងចូលទៅឯនាង និងមានបន្ទូលថា ***"ឱប្អូន ជាប្រពន្ធអើយ អញបានចូលមកក្នុងសួនច្បារហើយ...ឱប្អូន ជាមាសសំឡាញ់ ឱព្រាបរបស់អញ ជាអ្នកបរិសុទ្ធរបស់អញអើយ ចូរបើកទ្វារឲ្យអញផង"*** (បទចំរៀងនៃសាឡូម៉ូន ៥:១,២)។ នៅពេលដែលទ្រង់***បើកប្រដាប់គ្របបាំងនាង*** ទ្រង់នឹងដឹងថាតើនាងគឺជា***កូន ក្រមុំព្រះបន្ទូលព្រហ្មចារី*** ឬក៏អត់ ថាតើនាងបានកា***ន់តាមព្រះបន្ទូលរបស់ទ្រង់*** និងបាន***ស្មោះត្រង់*** ចមពោះទ្រង់ ឬក៏អត់។ បើសិនជានាងបានកំផិតជាមួយអ្នកដទៃ(ពាក្យរបស់មនុស្សផ្សេង) នោះភាពមិនស្មោះត្រង់ របស់នាងនឹងត្រូវ***បើកឲ្យឃើញ។*** (ត្រឹមត្រូវហើយគ្មានអ្នកថ្វាយបង្គំព្រះណា ដែលកំផិតជាមួយនឹងគោលលទ្ធិមនុស្សបង្កើត អាចឈរនៅក្នុងវត្តមាននៃព្រះរបស់ទ្រង់បានឡើយ)។ នោះពីយ៉ាងណាក៏ដោយ បើនាងបានកាន់តាមព្រះបន្ទូលរបស់ទ្រង់ នោះនាងនឹងបង្ហាញស

ប្បុរពិតរបស់នាង ជាកូនក្រមុំព្រះបន្ទូលពិតរបស់កូនកំលោះព្រះបន្ទូល។ ដោយសារទ្រង់បានប្រទានឲ្យនាងនូវសញ្ញាលោហិតជិត២០០០ទៅហើយ បានជាទ្រង់ចង់ឃើញ ភស្តុតាង នៃជីវិត នៃព្រះលោហិត របស់ទ្រង់នៅក្នុងនាង ពេលទ្រង់បើកប្រដាប់គ្របបាំងនាង។ ***នាងត្រូវតែបង្កើត អត្តសញ្ញាណរបស់នាង*** *ត្រាឬសញ្ញានៃព្រះវិញ្ញាណបរិសុទ្ធ* នៅក្នុងជីវិតរបស់នាង (អេភេសូរ ១:១៣-១៤)។ អាម៉ែន!

មែនហើយ កូនកំលោះព្រះបន្ទូលរបស់យើងនឹងបើកភ្លើង*(នៅពេលព្រឹក)*ពេលទ្រង់*បើកស្បៃ*និង *បើកប្រដាប់គ្របបាំង* កូនក្រមុំរបស់ទ្រង់នៅក្នុង*ជុបប៉ា*របស់ទ្រង់ (អូ ខ្ញុំ! វាជាម៉ោងដែលថ្ងៃកំពុងរះ!) ការត្រេកអរ ការរាំ ការច្រៀង ការស្រែកនៅក្នុងចំណោមពួកទៅតាមវិហារមានតែឈ្មោះ នឹងបន្តទៅទៀត។ ពួកគេភាគច្រើនមិនចាប់អារម្មណ៍នឹង*ការបរិភោគនៅឯតុនៃម៉ាណា* ដែលរៀបដោយកូនកំលោះទេ។ ពួកគេគ្រាន់តែចាប់អារម្មណ៍នឹង ដំណើរការនៃ ***អាពាហ៍ពិពាហ៍***-ភាពសប្បាយរីករាយនៃពួកខារីស្មាទិក និងភែនធីខសស្តលទូទាំងពីភពលោកប៉ុណ្ណោះ។ ប៉ុន្តែកូនក្រមុំបានទៅឯ*ការបរិភោគការ* និងត្រូវគេហែរហមទៅឯ***ជុបប៉ា*** ដើម្បីជួបនឹងកូនកំលោះព្រះបន្ទូលរបស់នាង។ ជាមួយនឹងភាពសប្បាយរីករាយនៃសកម្មភាពនៅថ្ងៃនោះខាងក្រោយពួកគេ កូនក្រមុំ និងកូនកំលោះកំពុងតែនៅក្នុងជុបប៉ាឥឡូវនេះហើយ ជាទីដែលមាន***សន្តិភាព ភាពស្ងៀបស្ងាត់ ការសំរាក និងកំលាំង។*** ទីនេះ



ហើយដែលកូនក្រមុំដេកនៅលើព្រះឧរាមាសសំឡាញ់តែ១របស់នាង ដោយខ្សិបថា ***"ឱបើប្តីនឹងថើបខ្ញុំ ដោយព្រះឱស្ឋទៅអេះពីព្រោះសេចក្តីស្រឡាញ់របស់ទ្រង់វិសេសជាងស្រាទំពាំបាយជូរ"*** (បទចំរៀងនៃសាឡូម៉ូន ១:២)។

អូ តើការប្រកបគ្នាអ្វីទៅន៏! ចំជាអំណរមកពីព្រះមែន! កូនកំលោះព្រះបន្ទូល និងកូនក្រមុំព្រះបន្ទូលបានជាប់នៅក្នុងបន្ទប់ទាំងអស់គ្នាក្នុងការថើប ឱបរឹតថ្នាក់ថ្នម, កូនក្រមុំកំពុងតែពឹងផ្អែកលើព្រះហស្តដ៏អស់កល្បនៃ

ព្រះគ្រីស្ទ និងកំពុងតែឮ សំលេងជាទីស្រឡាញ់ដ៏ទន់ភ្លន់របស់ទ្រង់ ដោយព្រះបន្ទូលដែលហូរមកដូចជា ប្រភពទឹក ដើម្បីនឹងលាងសំអាតវិញ្ញាណរបស់នាងនៃអត្តចារិកគ្មានបំនងចិត្ត ដូចជាកិច្ចការខាងសាច់ឈាម សេចក្តីព្រងើយកន្តើយ គំនិតខុសឆ្គង និងផ្សេងទៀត។ ពិតមែនហើយ ដែលឲ្យទ្រង់ស្គាល់នោះ គឺជាអំណរដែលរកថ្លែងពុំបាន និងពេញដោយសិរីល្អ!។

## កូនក្រមុំក្លាយទៅជាភរិយា

ប្រយោគ *"ភរិយាទ្រង់បានរៀបខ្លួនស្រេច"* នៅក្នុងវិវរណៈ ១៩:៧ ប្រាប់យើងថាកូនក្រមុំនៃព្រះគ្រីស្ទត្រូវតែក្លាយទៅជាភរិយានៅត្រង់ចំនុចជាក់លាក់១ នៃពេលក្នុងកំឡុងពេលអាពាហ៍ពិពាហ៍។ គឺនៅក្នុង *ជុបប៉ា* ដែកូក្រមុំក្លាយទៅជាភរិយា។ កូនក្រមុំមិនអាចក្លាយទៅជាភរិយាទេ បើសិនជា ***គ្មានការសេពសន្ថវ*** បានកើតឡើង។ ជាងនេះទៅទៀត វាជាក់ច្បាស់ពីប្រយោគនោះថា ភរិយាទ្រង់បានរៀបខ្លួនជាស្រេចដើម្បីអ្វី១។ ***តើវាជាអ្វី?***

រហូតមកដល់ ថ្ងៃនេះ កូនក្រមុំនៃអាពាហ៍ពិពាហ៍ ផ្នែកខាងអាស៊ីខ្លះ គឺត្រូវ*បង្ហាញថា* ជា*ភរិយា* នៅក្នុងកំឡុងពេលបរិភោគការចុងបញ្ចប់ និងចុងក្រោយដែលត្រូវធ្វើឡើងនៅផ្ទះកូកកំលោះ។ ការបរិភោគការដ៏ធំ គឺជាការដល់កំរិតខ្ពស់បំផុតនៃកិច្ចការវិវាហមង្គលទាំងមូល។ កូនក្រមុំត្រូវបំពាក់ដោយសំលៀកបំពាក់រៀបការខុសប្លែកទាំងស្រុងខុសពីសំលៀកបំពាក់ ដែលនាងបានស្លៀកពាក់សំរាប់ពិធីពីមុន។ ***សំលៀកបំពាក់រៀបការ*** នេះ ដែលជាធម្មតា ដេរដោយវត្ថុធាតុដើមល្អជាងគេ បង្ហាញថានាងលែងជាកូនក្រមុំទៀតហើយ ប៉ុន្តែជាភរិយាវិញ ដល់កំលោះនោះ។ ឥឡូវនេះ នាងបានពាក់គ្រឿងលំងកាន់តែប្រសើរ ឬមុដជំនួសស្បៃវិញដែលជាសញ្ញាបញ្ជាក់ថា នាងគឺជាមហាក្សត្រីយានី ពេលដែលនាងអង្គុយជាមួយព្រះមហាក្សត្ររបស់នាងនៅឯក្បាលនៃតុ ឬវេទិកាកិត្តិយស (នាងអេសធើរ ២)។ ស្រដៀងគ្នាដែរ មានខគម្ពីរជាច្រើនបង្ហាញថា ពួកបរិសុទ្ធនៃព្រះនឹងត្រូវតាំងឲ្យមានតំណែងដើម្បីអង្គុយជាមួយព្រះគ្រីស្ទទាំងអស់គ្នានៅលើបល្ល័ង្ករបស់ទ្រង់។

ឱពួកបរិសុទ្ធនៃព្រះអើយ បើសិនជាយើងពិតជាអវៈយវៈ នៃកូនក្រមុំរបស់ទ្រង់មែនដែលកំពុងទន្ទឹងរង់ចាំស្លៀកពាក់សំពត់ទេសយ៉ាងម៉ដ្ឋ ស្អាត ហើយស ***រ៉ូបនៃសេចក្តីសុចរិត*** នោះយើងនឹងបានរៀបខ្លួនជាស្រេចជាភរិយារបស់ទ្រង់ *(វិវរណៈ ១៩:៧-៨) ក៏ដូចជាយើងបានរៀបខ្លួនជាស្រេចជារបស់ទ្រង់ តាមរយៈព្រះរាជសារនៃទេវតាទី៧ និងបានចូលទៅក្នុងវិវាហមង្គលបច្ចុប្បន្ននេះ។* ហើយព្រះអម្ចាស់បានប្រទានមកយើងនូវ ***អំណោយទានពេលទ្រង់លើកឡើង***(Ascension Gifts)

ព័ន្ធកិច្ចនៃពួកសាវក ពួកហោរា ពួកគ្រូផ្សាយដំណឹងល្អ គ្រូគង្វាល និងគ្រូបង្រៀន ដើម្បីធ្វើឲ្យយើង គ្រប់លក្ខណ៍ ដោយព្រះ បន្ទូលរបស់ទ្រង់។ គឺ ជាព័ន្ធកិច្ច ១ ដែល លោកីយ៍នឹង មិនកត់សំគាល់ឡើយ។ ដូចជាបងប្រុសប្រាណហាំបាននិយាយថា វាជាព័ន្ធកិច្ចបន្ទាប់ខ្លួន។ វាជាព័ន្ធកិច្ចនៃ***សំលេងនៃមហាទេវតា***(១ថែស្សាឡូនិច ៤: ១៦)ដែលកំពុងនាំព្រះបន្ទូលរបស់ទ្រង់នៅមាសសម្លាញ់របស់ទ្រង់នៅក្នុង ***ជុបប៉ា*** ដើម្បីឲ្យនាងរៀបខ្លួនជាស្រេចសំរាប់ ពិធីលៀងវិវាហមង្គលដ៏ធំ នៅក្នុងស្ថានសួគ៌ ជាដំណាក់នៃប្ដីរបស់នាង។ អាម៉ែន! (ដូច្នេះ ពួកអ្នកជឿព្រះរាជសារចុងក្រោយ គឺ មិនគ្រាន់តែស្គាល់សំលេងនៃទេវតា (អ្នកនាំព្រះរាជសារ) ទៅ***យុគសម័យពួកជំនុំទី ៧*** ប៉ុណ្ណោះទេ គឺ នឹងស្គាល់សំលេងនៃមហាទេវតា ***(ចៅហ្វាយអ្នកនាំព្រះរាជសារ អ្នកនាំព្រះរាជសារដ៏ខ្លាំងពូកែ***-សូមមើលវិវរណៈ ១០:១) (ដែលឥឡូវនេះកំពុកតែ មានបន្ទូលទៅកូនក្រមុំរបស់ទ្រង់)។

តើអ្នកបានកត់សំគាល់ទេថា ដូចជាវិវាហមង្គលធម្មតាទេ ***ដំណើរការនៃវិវាហ មង្គល***នៃកូនចៀមគឺត្រូវប្រព្រឹត្តឡើងជាចំហ ប៉ុន្តែការរួមប្រកបនៃគូនេះ ដែលកំពុង តែកើតឡើងឥឡូវនេះហើយ កំពុងនៅក្នុងភាពឯកជននៃ***ជុបប៉ា?*** ការការពារនៃកូន ក្រមុំព្រះបន្ទូល ខាងវិញ្ញាណដោយព្រះបន្ទូល កើតឡើងនៅក្នុង***បន្ទប់ពិសេស*** នៃ ព្រះបន្ទូល ជាទីដែលកូនកំលោះនិងកូនក្រមុំចាប់ផ្ដើមស្គាល់គ្នាយ៉ាងស្និទ្ធស្នាល ***ការបើកសំដែង*** នៃអាថ៌កំបាំងនេះ ត្រូវលាក់ពីលោកីយ៍។ ពួកគេនឹងមិនបានដឹង ការនេះឡើយ។ ហើយពួកគេក៏មិនដឹងពីអាថ៌កំបាំងនៃ**ការលើកឡើងទៅលើនៃពួក បរិសុទ្ធ**នៅពេលត្រែចុងក្រោយបង្អស់នៃព្រះ (១ថែស្សាឡូនិច ៤:១៦)។ ដ្បិតម៉ោង នោះនឹងត្រូវសំដែងដល់នាងនៅទីនោះ។ នាងនឹង ត្រូវគេប្រាប់ពីពេល និងពីបែប ដែលរូបកាយខាងសាច់ឈាមរបស់នាងត្រូវផ្លាស់ប្រែ។ ***ផ្គរលាន់ទាំង៧ នៅក្រោម ត្រាទី៧*** នោះកាន់សេចក្ដីអាថ៌កំបាំងនោះ វាជាសេចក្ដីអាថ៌កំបាំង ដែលលោកីយ៍ នឹងមិនដែលបានស្គាល់ឡើយ]។

## ការសរុបបញ្ចប់

ដូច្នេះ ដរាបណាពិធីវិវាហមង្គលនៃកូនក្រមុំព្រះបន្ទូលនៅផែនដី និងកូន កំលោះព្រះបន្ទូលនៅស្ថានសួគ៌បានគ្រោងទុកហើយ ***ការបរិភោគការ*** នឹងបន្តរហូត ទាលតែស្ត្រីរើសតាំង ***"បានរៀបខ្លួនជាស្រេច"។*** បន្ទាប់មក ភរិយាជាកូនក្រមុំនឹង លើកយកទៅផ្ទះនៅឯដំណាក់ នៃប្ដីរបស់នាង ហើយ ត្រូវថ្វាយជាភរិយារបស់ទ្រង់ នៅឯ ***ការបរិភោគការ*** ចុងក្រោយ និងចុងបញ្ចប់ ***នៃកូនចៀម*** ដែលនឹងជាការសរុប បញ្ចប់នៃកិច្ចការវិវាហមង្គលដ៏វែងរវាង កូនចៀម និងភរិយារបស់ទ្រង់។

*"ចូរឲ្យយើងអរសប្បាយ ហើយរីករាយឡើង ទាំងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតបានដល់វិវាហមង្គលនៃកូនចៀមហើយ ភរិយាទ្រង់បានរៀបចខ្លួបជាស្រេច ទ្រង់ប្រទានឲ្យនាងបានស្លៀកពាក់សំពត់ទេសយ៉ាងម៉ដ្ឋ នោះជាសេចក្ដីសុចរិតរបស់ពួកបរិសុទ្ធ" (វិវរណៈ ១៩:៧-៨)។*

ហាលេលូយ៉ា! អាម៉ែន! ភរិយាកូនក្រមុំនៃកូនចៀមនឹងរៀបខ្លួនាងជាស្រេចបានយ៉ាងទៀងទាត់ ដោយម៉ោងនោះ និងសំរេចវិវរណៈ ៣:២១ ***"ឯអ្នកណា ដែលឈ្នះ នោះអញនឹងឲ្យអង្គុយលើបល្ល័ង្កជាមួយនឹងអញ ដូចជាអញបានឈ្នះ ហើយអង្គុយជាមួយនឹងព្រះវរបិតាលើបល្ល័ង្កទ្រង់ដែរ"។*** នាងនឹងមិនស្លៀកពាក់សំលៀកបំពាក់រៀបការនៃសេចក្ដីសង្គ្រោះតទៅទៀតទេ។ នាងនឹងបានបំពាក់ដោយសំលៀកបំពាក់រៀបការផ្សេងទៀត គឺជា សំពត់ទេសយ៉ាងម៉ដ្ឋ ***(រ៉ូប)នៃសេចក្ដីសុចរិត,*** អាម៉ែន។ បន្ទាប់មក នាងនឹងត្រូវថ្វាយ ជាភរិយាសុចរិតពិតនៃកូនចៀម។ សូមថ្វាយព្រះពរព្រះនាមព្រះអម្ចាស់! ហើយជាមួយនឹងមកុដនៃជីវិតនៅលើក្បាលនាង និងគ្រឿងលំអផ្សេងទៀត និងអំណោយនៅលើរូបកាយរបស់នាង(រង្វាន់បានប្រទានដល់នាងនៅឯ***បល្ល័ង្កជំនុំជំរះ នៃប្រះគ្រីស្ទ-រ៉ូម ៤:១០-១២)*** នាងនឹងអង្គុយជាមហាក្សត្រីយានី នៅក្បែរព្រះមហាក្សត្ររបស់នាង នៅក្នុងវត្តមាននៃពួកពលបរិវារនៅស្ថានសួគ៌ជាទេវតា នៅឯ***ពិធីលៀងវិវាហមង្គល***ដ៏ធំចុងក្រោយនៃ***កូនចៀម*** ប៉ុន្តែនៅខណៈ ដែលនាងបរិភោគ ជាមួយព្រះមហាក្សត្រ របស់នាងយ៉ាងរីករាយ នោះក៏នឹងមានគេយំរៀបរាប់ និងសង្កៀតធ្មេញនៅលើផែនដីដែរ។

## រាត្រីចន្ទ្រាទឹកឃ្មុំ

នៅពេលដែល ***ពិធីលៀងវិវាហមង្គល*** ដ៏ធំ ***នៃកូនចៀម*** នៅស្ថានសួគ៌បានចប់ហើយ និង***គ្រាមហាវេទនា*** នៅលើផែនដីបានចូលមកដល់ទីបញ្ចប់ ព្រះមហាក្សត្រ និងមហាក្សត្រីយានី នឹងយាងមកដោយជិះសេះសដើម្បីសងសឹកដល់ពួកមនុស្សអាក្រក់ និងដើម្បីកាត់ទោសដល់លោកីយ៍(សាការី ១៤:៤, វិវរណៈ ១៩:១១-១៨, ២០:៤)។ ហើយនៅចំពេលដែលនាងបង្ហាញខ្លួននាងនៅក្នុងផ្នែកខាងវិញ្ញាណនៃស្ថានសួគ៌ ព្រះមហាក្សត្រយានី ក៏នឹងបង្ហាញអង្គព្រះ នាងនៅក្នុងផ្នែក ខាងសាច់ឈាមនៃផែនដី(រ៉ូម៨:១៨-២៣)។ ផែនដីនឹងត្រូវសំអាតចេញពីគ្រប់ទាំងអំពើបាប និងភាពអាក្រក់។ នៅពេលដែលស្ថានភាពជិតអេដែន ត្រូវបានស្តារឡើងវិញ ផែនដីនឹងទៅជាស្ថានបរមសុខម្តងទៀត (អាសាយ ៦៥:១៨-២៥)។ នោះហើយគឺជាការចាប់ផ្តើមនៃ ***យុគសម័យនៃការកែជំនាន់មនុស្សជាថ្មី (ម៉ាថាយ១៩:២៨) និងការសោយរាជ្យ១សហសវត្សរ៍ (១ពាក់ឆ្នាំ)នៃព្រះមហាក្សត្រ និង មហាក្សត្រីយានីរបស់***

វិវាហមង្គលនៃកូនចៀម

***ទ្រង់។*** វាគឺជាកំឡុងពេល ***រាត្រីចន្ទ្រាទឹកឃ្មុំ*** សំរាប់គូស្វាមីភរិយាថ្មោងថ្មី។ ការទាំងអស់នេះគឺជាសេចក្តីទំនាយ ដែលបានកត់ត្រានៅក្នុងបទគម្ពីរដ៏ពិសិដ្ឋនៃព្រះអម្ចាស់យេស៊ូគ្រីស្ទរបស់យើង។ ប៉ុន្តែ នៅពេលចន្លោះ សូមឲ្យពាក្យទាំងនេះ ដែលយ៉ូហានជាមាសសម្លាញ់ត្រូវបានគេដាស់តឿនឲ្យសរសេរឡើង រោទិ៍នៅក្នុង ចិត្តរបស់អ្នក ជាការអញ្ជើញៈ ***"មានពរហើយដែលព្រះបានហៅមកបរិភោគការកូនចៀម" វិវរណៈ ១៩:៩)។***

តើអ្នកនឹងទទួល ***ការអញ្ជើញ*** និងរៀបខ្លួនជាស្រេចសំរាប់ ***បរិភោគការកូនចៀម (ពិធីលៀងវិវាហមង្គលនៃកូនចៀម)*** ដែរឬទេ?

> នៅពេលទ្រង់បិទទ្វារ ក៏មានបន្ទូលមកខ្ញុំ យ៉ាងពិរោះក្នុងបន្ទប់ យកវិញ្ញាណបរិសុទ្ធទទេ ម្ចាស់ស្នេហ៍ស្ថានសួគ៌អើយ សូមវត្តមានទ្រង់គ្របបាំង ស្នេហ៍ខិណាឥតដែលចប់ ដែលខ្ញុំរកចង់បាន។
>
> យាងមកម្ចាស់ស្នេហ៍ខ្ញុំ ជាព្រះអម្ចាស់ ជាម្ចាស់ខ្ញុំ ពេលខ្ញុំថ្វាយខ្លួនខ្ញុំ ឲ្យខ្ញុំរួមនឹងទ្រង់ សូមព្រះបន្ទូលបរិសុទ្ធ របស់ទ្រង់ហ៊ុំព័ទ្ធខ្ញុំការពារខ្ញុំគាំពារខ្ញុំនិងគ្របបាំងខ្ញុំ


ការយាងមកនៃព្រះគ្រីស្ទមកយកកូនក្រមុំទ្រង់
ឬ
វិវាហមង្គលនៃកូនចៀម
ផ្ទះកូនកំលោះ
ពិធីលៀងវិវាហមង្គល
នៃកូនចៀម
" ត្បិតមានដល់ពេលរៀបវិវាហមង្គលនៃកូន
ចៀមហើយ ភរិយាទ្រង់ បានរៀបខ្លួនជាស្រេច
ទ្រង់បាន
ប្រទានឱ្យនាង
ស្លៀកពាក់
សំពត់ទេស
យ៉ាងម៉ដ្ឋស្អាត
ហើយភ្លឺ "
អេពីដានៀ
អេពីដានៀ
ការនៅផ្ទះ
សំរែក!-
នែ ប្ដីមកហើយ!
ចូរចេញទៅទទួលចុះ!
ជិតដល់
កណ្ដាលអធ្រាត្រ
ការបរិភោគ
វិវាហមង្គល
បន្ទប់ពិសេស
សំលេងនៃមហាទេវតា
"ខ្ញុំម្ចាស់ជារបស់ផងស្ងួនសំឡាញ់នៃខ្ញុំ
ហើយទ្រង់មានសេចក្តីប៉ងប្រាថ្នាចំពោះខ្ញុំម្ចាស់"
កណ្ដាលអធ្រាត្រ
APOKALUPSIS
អាប៉ូកាឡិបស៊ីស

វិវាហមង្គលនៃកូនចៀម

## សេចក្តីផ្តើម

មានអ្នកជឿគម្ពីរជាច្រើនមានការពិបាកក្នុងការយល់**អាថ៌កំបាំង**នៃ***វិវាហមង្គល នៃកូនចៀម*** នៅពេលដែលពួកគេសិក្សាបទគម្ពីរពិសេស៣នៅក្នុងគម្ពីរ ដោយយោងទៅតាម ប្រធានបទនោះ។

បទគម្ពីរទូទៅជាងគេគឺ វិវរណៈ ១៩:៩។ ខនេះត្រូវបានបកស្រាយដោយទេវវិទូខ្លះថា ***ជាការអញ្ជើញ១*** ដែលបន្តទៅដល់ក្រុមភ្ញៀវ១ ដែលមិនមែនជាសមាជិកនៃកូនក្រមុំ។ ពួកគេបានថ្លែងថា ព្រះរាជបុត្រានៃព្រះ និងកូនក្រមុំរបស់ទ្រង់នឹងគ្រាន់តែរៀបការនៅពេលវិលត្រឡប់មកផែនដីវិញ បន្ទាប់ពី***គ្រាមហាវេទនា*** ហើយថាក្រុមភ្ញៀវនេះ នឹងត្រូវអញ្ជើញដើម្បីបរិភោគ***ការកូនចៀម*** (ពិធីលៀងវិវាហមង្គលនៃកូនចៀម)។

ពួកគេនឹងប្រើម៉ាថាយ ២២:១-១៤ និង ២៥:១-១៣ ដែលជាពាក្យប្រៀបប្រដូចអំពី ***ការបរិភោគការ និងព្រហ្មចារី១០នាក់*** ជាការគោរព ដើម្បីគាំទ្រដល់ការបកស្រាយរបស់ពួកគេ។ ពួកគេនឹងចង្អុលទៅបុត្រារបស់ស្តេច កូនក្រមុំ (ដែលបញ្ជាក់នៅក្នុងពាក្យប្រៀបប្រដូច) និងភ្ញៀវ នៅក្នុងពាក្យប្រៀបប្រដូចពីមុន។ ពួកគេក៏ជឿដែរថា **ព្រហ្មចារី១០**នាក់ដែលជាស្រីបំរើនៅក្នុងវត្តមាននៅចំពោះកូនក្រមុំ គឺពិតជាក្រុមមនុស្សផ្សេងទៀត នៅក្នុងពិធីរៀបមង្គលការ។

សេចក្តីខុសឆ្គងបានកើតឡើង ពីការបកស្រាយ អត្ថបទខុសរបស់ពួកគេ។ អានវិវរណៈ ១៩:៦-៩ ដោយប្រុងប្រយ័ត្ន និងចំណាំថា យ៉ូហានជាមាសសំឡាញ់ ដែលបានលើកឡើងទៅក្នុងវិញ្ញាណ បានឃើញការជាក់ស្តែង(និម្មិត)អស្ចារ្យជាច្រើន។ នៅចំណោមការផ្សេងទៀត គាត់ក៏បានឮសំលេងយ៉ាងខ្លាំងបន្លឺឡើងជាផ្គរលាន់ផងដែរ ដោយនិយាយថាៈ

*"ហាលេលូយ៉ា ដ្បិតព្រះអម្ចាស់ដ៏ជាព្រះ ដែលមានព្រះចេស្តាបំផុត ទ្រង់សោយរាជ្យឡើងហើយ ចូលឲ្យយើងអរសប្បាយ ហើយរីករាយឡើង ទាំងថ្វាយសិរីល្អដល់ទ្រង់ចុះ ដ្បិតបានដល់ពេលរៀបវិវាហមង្គលនៃកូនចៀម ហើយភរិយា ទ្រង់បានរៀបខ្លួនជាស្រេច ទ្រង់ប្រទានឲ្យនាង បានស្លៀកពាក់សំពត់ទេសយ៉ាងម៉ដ្ឋ នោះជាសេចក្តីសុចរិតរបស់ពួកបរិសុទ្ធ"។*

បន្ទាប់មកក្រោយពីការប្រកាសរួច ទេវតានោះដែលទៅជាមួយយ៉ូហាន បានទូន្មានគាត់ឲ្យកត់ការអញ្ជើញនៅខាងក្រោមនេះ

***"មានពរហើយ អស់អ្នកដែលព្រះបានហៅមកបរិភោគការកូនចៀម"។***

បន្ទាប់មកក្រោយពីការប្រកាសរួច ទេវតានោះដែលទៅជាមួយយ៉ូហាន បានទូន្មានគាត់ឲ្យកត់ការអញ្ជើញនៅខាងក្រោមនេះ

***"មានពរហើយ អស់អ្នកដែលព្រះបានហៅមកបរិភោគការកូនចៀម"។***

ការប្រកាសទាំង២នេះ ត្រូវតែបរិយាយដាច់ដោយឡែកពីគ្នា និងមើលនៅក្នុងបរិបទដ៏ត្រឹមត្រូវ។ អស់អ្នកដែលត្រូវបានហៅមកបរិភោគការ គឺជាមនុស្សមានពរ, ពួកគេជាក្រុមដដែល **(ពួកយូដាដែលត្រូវបានប្រាប់លើកទី១)** បានបដិសេធការអញ្ជើញនោះ ផ្តែកទៅលើម៉ាថាយ ២២:១-១៤។ ហើយយើងដឹងថា ម៉ាថាយ ២២:១-១៤ *គឺជាពាក្យប្រៀបប្រដូច។* ពាក្យប្រៀបប្រដូចក្នុងគម្ពីរគឺជារឿងនិទាន ដែលប្រើ ដើម្បីបង្ហាញពីសេចក្តីពិតជាក់លាក់។ ដើម្បីយល់ការនេះឲ្យបានត្រឹមត្រូវ គឺត្រូវតែបកស្រាយក្នុងគម្រោងនៃខ្លឹមសារជាក់លាក់។ ដូច្នេះនៅក្នុងការអានពាក្យប្រៀប**ប្រដូចនៃម៉ាថាយ ២២:១-១៤** យើងសំគាល់ថា ខ្លឹងសារនេះ គឺអំពីស្តេច ដែលបានរៀបចំពិធីលៀងសំរាប់បុត្រារបស់ទ្រង់។ វាមិនមែនអំពីបុត្រារបស់ទ្រង់ និងកូនក្រមុំទេ។ ***គឺដូចជាពួកបរិសុទ្ធនៃព្រះ*** ត្រូវបានពិពណ៌នាដោយប្រៀបធៀបថាជាពួកថ្មរស់ ឬជា **អវៈយវៈ**ផ្សេងគ្នានៃ***រូបកាយ១*** ពួកគេក៏ត្រូវបានពិពណ៌នាដូចគ្នាថា ជា**ពួកភ្ញៀវ**នៅក្នុងពាក្យប្រៀបប្រដូចនេះ។

នៅពេលដែលយើងស្គាល់ ការប្រើប្រាស់នៃពាក្យប្រៀបប្រដូច ក្នុងគម្ពីរទាំងអស់នោះ យើងអាចយល់ថា ពួកបរិសុទ្ធ ដែលប្រមូលផ្តុំបង្កើតជា **ព្រះវិហារពិត១** ហៅថា កូនក្រមុំនៃព្រះគ្រីស្ទ។ ហើយពេលយើងពិពណ៌នាអំពីពួកបរិសុទ្ធថាជាកូនក្រមុំនៃព្រះគ្រីស្ទ នោះពួកគេលែងជាភ្ញៀវ ទៀតហើយ។ ហេតុអ្វី? គឺមានមូលហេតុជាក់ស្តែង។ កូនក្រមុំ ទាក់ទងនឹង កូនកំលោះ រីឯភ្ញៀវ ទាក់ទង នឹងការបរិភោគ(ពិធីលៀងវិវាហមង្គល)។

ដោយឥឡូវនេះ យើងគួរដឹងហើយថា ការអញ្ជើញ នៃវិវរណៈ ១៩:៩ បានបន្ត ជាសេចក្តីទំនាយ **ដល់ក្រុមជាក់លាក់១** ដែលជាភ្ញៀវមានពរ នៅឯពិធីលៀងវិវាហមង្គលដ៏ធំ នៃកូនចៀម។ ចូរចំណាំថា (នៅក្នុងម៉ាថាយ ២២:១-១៤) មានមនុស្សជាក់លាក់ម្នាក់នៅឯពិធីលៀងវិវាហមង្គល ត្រូវបោះចេញ ***"ទៅក្នុងភាពងងឹតនៅខាងក្រៅ"*** ពីព្រោះ គាត់អត់មានសំលៀកបំពាក់រៀបការ ត្រឹមត្រូវ។
គាត់ពិតជាមិនមែនជាភ្ញៀវ ដែលមានពរទេ។ មែនហើយ វិវរណៈ ១៩:៦-៨គឺជាការប្រកាស១ ដែលពិធីលៀងវិវាហមង្គលនៃកូនចៀម នឹងកើតឡើងជាឆាប់។ អ្នកខ្លះអាចឆ្ងល់ថាតើហេតុអ្វីបានជាខ្ញុំប្រើពាក្យ "***ពិធីលៀងវិវាហមង្គលនៃកូនចៀម***" ជំនួស "***វិវាហមង្គលនៃកូនចៀម***" ដូចដែលបានបោះពុម្ពនៅក្នុងគម្ពីរយើងចេម្ស។ ពាក្យក្រិកគឺ*ហ្គាម៉ុស(gamos)។* ពាក្យនេះអាច បកប្រែថា វិវាហមង្គលអាពាហ៍ពិពាហ៍ ឬពិធីលៀងវិវាហមង្គល។(នៅក្នុងជំនាន់គម្ពីរជាក់លាក់ ត្រូវបានបកប្រែថា ពិធីលៀងវិវាហមង្គល ឬ ការបរិភោគការ)។ ទោះបីយ៉ាងណាក៏ដោយ ពាក្យ ភរិយា **(ពាក្យក្រិក ហ្គូន (gamos))**ចង្អុលទៅរករឿងពិតដែលបានសំរេច ដែលមាសសម្លាញ់កូនក្រមុំ(**ពាក្យក្រិកនុមហ្វេ**(Numphe) ពិតជាបានក្លាយទៅជា **ភរិយា** របស់កូនចៀម (វិវរណៈ ២១:២,៩)។ ក៏មានប្រយោគ២ផ្សេងទៀត ដែលគាំទ្ររឿងនេះ "*ភរិយារបស់ទ្រង់បានរៀបខ្លួនជាស្រេច*"

## វិវាហមង្គលនៃកូនចៀម

និង "*ទ្រង់ប្រទានឲ្យនាងបានស្លៀកពាក់សំពត់ទេសយ៉ាងម៉ដ្ឋ ស្អាតហើយភ្លឺ ...*"។ នៅក្នុងពិធីរេបការផ្នែកខាងអាស៊ីពីបុរាណ កូនក្រមុំត្រូវបានបង្ហាញថា ជាប្រពន្ធ និងជាមហាក្សត្រីយានី នៅឯពិធីលៀវិវាហមង្គល **ដ៏ធំ** ប៉ុណ្ណោះ និងមិនដែលមុនពេលនោះទេ។ នៅពេលដែលស្ត្រីម្នាក់ត្រូវបានដណ្តឹងឲ្យបុរសម្នាក់ទៀត នាងគ្រាន់តែជាប្រពន្ធដែលមានសក្តានុពល ប៉ុណ្ណោះ។ ជាការពិត នាងក្លាយជាប្រពន្ធរបស់គាត់ ក្រោយពីពិធីនៃបន្ទប់ពិសេសប៉ុណ្ណោះ។

ព្រហ្មចារី១០នាក់ នៅក្នុពាក្យប្រៀបប្រដូចនៃម៉ាថាយ២៥:១-១៣ គឺជាស្រីបំរើមានវត្តមាន នៅចំពោះកូនក្រមុំ។ ពួកគេត្រូវហៅថា ពួកព្រហ្មចារីនៅក្នុងពាក្យប្រៀបប្រដូច ពីព្រោះ នៅក្នុងអាពាហ៍ពិពាហ៍ផ្នែកខាងអាស៊ី ស្រីបំរើមានវត្តមានត្រូវសន្មតិថាមិនទាន់បានរៀបការ ហើយក្មេងជាកូនក្រមុំ។ ជាធម្មតា កូនក្រមុំផ្ទាល់ជាអ្នករើសពួកគេ ដើម្បីធ្វើជា មិត្តសម្លាញ់របស់នាងនៅពេលរៀបអាពាហ៍ពិពាហ៍។ នៅពេលដែលបានកំនត់ទុក ស្រីបំរើទាំងនេះនឹងចេញទៅជំរាបសួរ និងទទួលកូនកំលោះក្នុងកំឡុងពេលដំណើររបស់គាត់ទៅផ្ទះកូនក្រមុំ។ ពួកគេនឹងដឹកនាំក្រុមមនុស្សនោះទៅឯកន្លែង ដែលគេរៀបចំវិវាហមង្គល និងការបរិភោគ។ (នៅក្នុងពាក្យប្រៀបប្រដូចនេះ **ការបរិភោគការ** ត្រូវបានរៀបចំ ដោយឪពុកម្តាយរបស់កូនក្រមុំ)។ ដោយសារតែជាធម្មតាពិធីនេះត្រូវប្រព្រឹត្តឡើងនៅពេលល្ងាចនោះគេក៏ត្រូវការភ្លើង (ពន្លឺ)ដែរ។ ចង្កៀងមានប្រេងត្រូវបានប្រើនៅក្នុងពាក្យប្រៀបប្រដូចទោះជាចន្លុះឆេះមានលក្ខណៈរួមច្រើនជាងក៏ដោយ។

ព្រះអម្ចាស់យើងបានប្រើអ្នកបំរើព្រហ្មចារីនេះ ដើម្បីតំណាងឲ្យកូនដែលកើតពីវិញ្ញាណនៃព្រះ។ ពាក្យប្រៀបប្រដូចនេះបង្ហាញនូវចំណង់របស់ពួកគេ ដើម្បីជួបកូនកំលោះ និងដើម្បីទទួលទ្រង់ទៅឯពិធីរៀបមង្គលការ ជាទី ដែលពួកគេនឹងមាន *ចំណែក* នៅឯតុកំពុងជុបលៀង។ ពួកគេបរិសុទ្ធក្នុងសេចក្តីជំនឿរបស់ព្រះគ្រីស្ទ។ ពួកគេជាក្រុមស្រូវសាឡី នៅក្នុងពាក្យប្រៀបប្រដូច ស្រូវសាឡី និង ស្រងែ នៅក្នុង ម៉ាថាយ ១៣:២៤-៣០។ យោងទៅតាមពាក្យប្រៀបប្រដូចនោះ មានស្ត្រីព្រហ្មចារីឆ្លាត៥នាក់ ដែលចេញទៅជួបកូនកំលោះ។ យ៉ាងម៉េចក៏ដោយ នៅពេលដែលកូនកំលោះបានពន្យាពេល ពួកគេបានធ្លាក់ទៅក្នុងភាពងោកងុយ ហើយដេកលក់ទៅ (នៅក្នុងពួកជំនុំនិយម) រហូតដល់សំរែក១ ***(សំលេងនៃអ្នកនាំព្រះរាជ្យសារទៅយុគសម័យពួកជំនុំទី៧)*** បានដាស់ពួកគេឡើងនៅកណ្តាលអាធ្រាត្រ (ប្រហែលឆ្នាំ ១៩៥៦)។ បន្ទាប់ ពួកគេទាំងអស់បានចាប់ផ្តើមរៀបចំប្រឆេះចង្កៀងរបស់ពួកគេរៀងខ្លួន (ការយល់ដឹង និងការបើកសំដែងនៃព្រះបន្ទូល)។ ទោះបីជាយ៉ាងណាក៏ដោយ មានតែពួកស្ត្រីព្រហ្មចារីឆ្លាតទេ ដែលមានប្រេង**សាគួរ(ព្រះវិញ្ញាណ)** នៅក្នុងភាជន៍របស់ពួកគេ អាចជួបនឹងកូនកំលោះ និងចូលទៅក្នុងសាលជុបលៀង ដែលជាកន្លែង ដែល ***ពិធីវិវាហមង្គល*** ត្រូវប្រព្រឹត្តឡើង។ ដូច្នេះ ពួកបរិសុទ្ធពិតនៃព្រះ ត្រូវបានពិពណ៌នានៅក្នុងពាក្យប្រៀបប្រដូច ថាជាពួកព្រហ្មចារី ដែលទាក់ទង ទៅនឹងព្រះសង្គ្រោះរបស់ពួកគេ ***ព្រះបន្ទូលបរិសុទ្ធ។***

ទំនាយ ដែលបានបើកសំដែង



សត្វឥន្ទ្រីស្រែក...





...សត្វព្រាបនាំ

**PROPHETIC*REVELATION**
**Ghim Moh Estate Post Office Box 333**
**Republic of Singapore 912742**